

# បំរែបំរួលអាកាសធាតុ, កម្មវិធី REDD+ និង ជនជាតិដើមភាគតិច នៅតំបន់អាស៊ាន



AIPP

IWGIA





## ជនជាតិដើមភាគតិចនៅតំបន់អាស៊ាន

ប្រជាពលរដ្ឋ នៅតំបន់អាស៊ានកំពុងប្រើប្រាស់ពាក្យជនជាតិដើមភាគតិចច្រើនឡើងៗ ដែលកន្លងមកពួកគេហៅថា កុលសម្ព័ន្ធភ្នំ ឬជនជាតិភាគតិចហើយនិងមានឈ្មោះ ផ្សេងៗគ្នាដទៃទៀតនៅក្នុងតំបន់ និងភាសារបស់ពួកគេ។

មូលហេតុ សម្រាប់ការប្រើប្រាស់ពាក្យនេះមានលក្ខណៈខុសៗគ្នា។ លើសពីនេះទៅទៀត ខណៈពេលដែលជនជាតិដើមភាគតិចប្រឈមមុខនឹងការរើសអើង និងការដាក់អោយនៅដាច់ដោយឡែកពីគេ ដូចប្រជាជនភាគតិចដទៃទៀត ក៏មានភាពខុសគ្នាដទៃទៀត ទាក់ទងសិទ្ធិ និងអត្តសញ្ញាណ។

ជនជាតិភាគតិច ជាញឹកញាប់ទទួលរងការរើសអើង ហើយពួកគេបានតស៊ូ ពុះពារ ដើម្បីទទួលការការពារសិទ្ធិរបស់ពួកគេ និងដើម្បីឲ្យពួកគេអាចចូលរួមសកម្មភាពសង្គម។ អង្គការសហប្រជាជាតិបានឆ្លើយតបយ៉ាងសមស្រប ហើយបានអនុម័តសេចក្តីប្រកាស្តីអំពីសិទ្ធិប្រជាពលរដ្ឋ ដែលជាសមាជិករដ្ឋ ឬ ជនជាតិភាគតិចខាងផ្នែកសាសនានិងភាសា ។

ចំនុចសំខាន់ដែលគួរគត់សំគាល់នៅត្រង់នេះគឺថា សេចក្តីប្រកាសស្តីអំពីជនជាតិភាគតិច គឺសំដៅលើសិទ្ធិបុគ្គលនិមួយៗនៃសមាជិកជនជាតិភាគតិច ។

តែទោះបីជាយ៉ាងណាក៏ដោយ ជនជាតិដើមតែងលើកឡើងពីតំរូវការដែលចង់ឲ្យមានការទទួល ស្គាល់សិទ្ធិជារួមរបស់ពួកគេ។ ហើយសិទ្ធិជារួមទាំងនេះ ត្រូវទទួលស្គាល់ដោយសេចក្តីប្រកាសអង្គកាសហប្រជាជាតិស្តីអំពីសិទ្ធិជនជាតិដើមដែលហៅកាត់ថា UNDRIP ដែលត្រូវអនុម័តដោយ មហាសន្និបាតអង្គការសហប្រជាជាតិឆ្នាំ២០០៧។ UNDRIP បានកំណត់ស្តង់ដារអតិប្បរមាសម្រាប់ការការពារសិទ្ធិជារួមរបស់ជនជាតិដើមភាគតិច។ ប្រជាជនជាច្រើននៅតំបន់អាស៊ានបានដឹងថា ពួកគេត្រូវគេរើសអើង និងកេងប្រវ័ញ្ចដោយបណ្តាក្រុមមនុស្សដទៃទៀត ដែលតាំងខ្លួនជាម្ចាស់ស្រុក។ ពួកគេយល់ថាពាក្យ (ជនជាតិដើមភាគតិច) ឆ្លុះ

បញ្ចាំងកាន់តែខ្លាំងពីកាលៈទេសៈជាក់លាក់ពិសេស និងរូបភាពនៃការរើសអើងដែលពួកគេប្រឈមមុខ នឹងបានធ្វើការសន្និដ្ឋានថា UNDRIP ប្រើពាក្យសមរម្យជាងបណ្ដាអង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ ដើម្បីជួយដោះស្រាយបញ្ហារបស់ពួកគេ។ ជនជាតិដើមភាគតិចមានភាសាវប្បធម៌ ហើយនឹងស្ថាប័នសង្គម និងនយោបាយខុសគ្នា។ នៅពេលដែលពួកគេតាំងខ្លួនជាជនជាតិដើមភាគតិច ពួកគេមិនចាំបាច់អះអាងខ្លួនថាជាមនុស្សដែលមានដើមកំណើតក្នុងរបស់ប្រទេសពួកគេនោះទេ។ ក្នុងករណីជាច្រើន ជនជាតិដើមភាគតិចពិតជាម្ចាស់ស្រុកដែលកាន់កាប់ដីដែលពួកគេតាំងទីលំនៅ។ ប៉ុន្តែអស់រយៈពេលជាច្រើនសតវត្សមកហើយ ពួកគេរស់នៅជាមួយបណ្ដាប្រជាជនដទៃទៀត ដែលពួកគេភាគច្រើនមានឥទ្ធិពលលើផ្នែកសេដ្ឋកិច្ច និងនយោបាយ ហើយឥលូវនេះពួកគេទាំងនោះបានកាន់កាប់អំណាចសេដ្ឋកិច្ច និងនយោបាយនៅក្នុងបណ្ដារដ្ឋដែលមានការរីកចំរើនជាច្រើន ដែលបានលិចចេញជារូបរាងអស់រយៈពេលមួយសតវត្សរ៍កន្លងមកនេះ ។ ជនជាតិដើមភាគតិច ប្រមាណពីរភាគបីក្នុងចំណោមប្រជាពលរដ្ឋជនជាតិដើម ៣០០ លាននាក់ ទូទាំងពិភពលោករស់នៅក្នុងទ្វីបអាស៊ី។

តែទោះបីជាយ៉ាងណាក៏ដោយ មានរដ្ឋតិចតួចណាស់នៅអាស៊ីអាគ្នេយ៍ ដែលទទួលស្គាល់សិទ្ធិប្រជាពលរដ្ឋជនជាតិដើម ប្រសិនបើបណ្ដារដ្ឋទាំងនោះ ទទួលស្គាល់សិទ្ធិពួកគេក៏ដោយក៏អត្តសញ្ញាណរបស់ពួកគេមិនត្រូវបានគេយកមកធ្វើការពិចារណាកំឡុងពេលធ្វើការរៀបចំធ្វើជំរឿនជាតិនោះទេ ។ ហេតុដូច្នេះហើយ គេពិបាកផ្ដល់តួរលេខត្រឹមត្រូវ ឬសូម្បីតែតួលេខប្រហាក់ប្រហែលនៃអត្រាប្រជាពលរដ្ឋជនជាតិដើមភាគតិចនៅក្នុងតំបន់អាស៊ាន ក៏មិនអាចផ្ដល់បានដែរ។ អត្រាប្រជាជននៃជនជាតិដើមភាគតិចនៅតំបន់អាស៊ាន ប្រហែលអាចមានចំនួនច្រើនដល់ទៅ ឬច្រើនជាង ១០០ លាននាក់ ។[១]









# ផលប៉ះពាល់នៃបំរែបំរួលបរិយាកាសមកលើតំបន់ និងជនជាតិដើមភាគតិចអាស៊ាន

គេចាត់ទុកតំបន់អាស៊ាន ជាតំបន់មួយដែលងាយទទួលរងផលប៉ះពាល់ពីបំរែបំរួលបរិយាកាសក្នុងចំណោមតំបន់ដែលងាយរងគ្រោះជាច្រើននៅក្នុងពិភពលោក។ បញ្ហានេះកើតឡើង ដោយសារតែអត្រាប្រជាជន និងសកម្មភាពសេដ្ឋកិច្ចរបស់តំបន់អាស៊ានផ្តោតទៅលើតំបន់ឆ្នេរដ៏វែងរបស់ខ្លួន ហើយសេដ្ឋកិច្ចរបស់តំបន់នេះនៅតែពឹងផ្អែកទាំងស្រុងលើវិស័យ កសិកម្ម និងធនធានធម្មជាតិ។ ការសិក្សាមួយដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ីនៅឆ្នាំ ២០០៩ បានសន្និដ្ឋានថា តំបន់អាស៊ាន គឺទំនងប្រហែលជាទទួលរងផលប៉ះពាល់បំរែបំរួលបរិយាកាសខ្លាំងជាងបណ្តារតំបន់ដទៃទៀតនៅលើពិភពលោក ប្រសិនបើគ្មានការចាត់វិធានការទប់ស្កាត់នោះទេ។[២]

ការកើននៃនីវ៉ូទឹកសមុទ្រ ដែលគេព្យាករណ៍ទុកនេះបានបង្ករគ្រោះថ្នាក់គំរាមកំហែង ដែលនឹងជិតកើតមានឡើងដល់ជីវិតមនុស្សរាប់លានអ្នកដែលរស់នៅតំបន់ឆ្នេរសមុទ្រ និងបណ្តារតំបន់កសិកម្មសំខាន់ៗដែលមានដីល្បាប់ដ៏មានជីជាតិ។

យោងតាមរបាយការណ៍វាយតម្លៃលើកទី៤ នៃក្រុមអន្តររដ្ឋាភិបាលស្តីពីបំរែបំរួលបរិយាកាសឆ្នាំ ២០០៧ ប្រទេស[៣] នៅក្នុងតំបន់អាស៊ានត្រូវគេរំពឹងទុកថានឹងត្រូវទទួលរងការកើនឡើងទឹកភ្លៀងជាខ្លាំង ដែលបង្កឲ្យមានគ្រោះទឹកជំនន់ជាប្រចាំ ហើយនឹងទទួលរងនិងការកើនឡើងខ្យល់ជាខ្លាំង ដែលបណ្តាលមកពីចលនាបាតុភូត ElNino ខាងត្បូងដែលហៅកាត់ថា ENSO ។ ENSO ត្រូវគេរំពឹងទុកថានឹងមានប្រពលភាពកាន់តែធំឡើងជាងមុននៅពេលអនាគត ដែលនឹងបង្កឲ្យមានគ្រោះរាំងស្ងួតរយៈពេលវែង ការដាំដំណាំមិនដុះ និងភ្លើងឆេះព្រៃកាន់តែមានទ្រង់ទ្រាយធំជាងមុនដែលអាស៊ានបានជួបប្រទះកន្លងមក។

### ប្រទេសឥណ្ឌូនេស៊ីៈ បំរែបំរួលដែលសង្កេតដោយ Dayak & Punan

Dayak បានធ្វើកំរោងឯកសារស្តីពីបំរែបំរួលបរិយាកាសដោយផ្អែកលើសន្ទស្សន៍បុរាណជាច្រើនដោយរួមមានប្រភេទពូជបក្សី ការកើនឡើងកម្រិតទឹក និងរុក្ខជាតិថ្នាំបុរាណ។ ពួកគេបានធ្វើការសង្កេតពូជបក្សី ដែលពួកគេមិនដែលឃើញពីមុនមក។ ពួកគេបានដឹងថា កម្រិតទឹកនៅក្នុងទន្លេខ្ពស់ជាង ឬទាបជាងធម្មតា សម្រាប់រដូវនេះ ហើយពួកគេបាន ដឹងថា រុក្ខជាតិបុរាណដែលគេប្រើជាឱសថព្យាបាលលែងមានទៀតហើយ។ អាកប្បកិរិយា និងគំរូការធ្វើចំណាក ស្រុករបស់បក្សី ដែលតាំងពីបុរាណត្រូវបានគេប្រើ ដើម្បីផ្តល់ជាសញ្ញាដល់ការធ្វើការប្រមាញ់ និងសកម្មភាពដាំដុះលែងផ្តល់មគ្គុទេស៍ដ៏គួរឲ្យទុកចិត្តទៀតហើយ។ សហគមន៍បរបាញ់ និងប្រមែប្រមូលផលដែលនៅតំបន់កាលីម៉ាន់តាន់ខាងកើត គឺជាប្រជាជនភូណាន់។ ប្រជាជនទាំងនេះធ្វើការសម្រេចចិត្តជ្រើសរើសធ្វើសកម្មភាពជាច្រើនដូចជា កសិកម្មដាំដុះដំណាំ កាប់ឆ្ការតំបន់ដាំដុះការប្រមាញ់។ល។ ដោយផ្អែកលើដំណើរព្រះច័ន្ទ។ តែទោះបីជាយ៉ាងណាក៏ដោយ ដោយមានបំរែបំរួលបរិយាកាស សញ្ញាណនៃព្រះច័ន្ទគតិទាំងនេះ លែងកើតឡើងស្របពេល ដ៏អំណោយផលសម្រាប់សកម្មភាពទាំងអស់ នេះទៀតហើយ ហើយប្រជាជនភូណាន់អាចនឹងធ្វើការសម្រេចចិត្តខុសដោយសារតែបញ្ហានេះ។

*ដកស្រង់ចេញពី Galloway Mclean,2009 ទំព័រ: 59*





## ប្រទេសម៉ាឡេស៊ីៈ ផលប៉ះពាល់នៃបំរែបំរួលបរិយាកាស មកលើការរស់នៅភូមិ Dayak Bidayuh-Jogoi នៃតំបន់ Dujoh ក្នុងខេត្តសារ៉ាវ៉ាក់

ការរស់នៅតាមបែបបុរាណ និងសកម្មភាពសេដ្ឋកិច្ចដទៃទៀតនៃជនជាតិដើម ក៏ត្រូវប៉ះពាល់ជាខ្លាំងផងដែរ ដោយសារបំរែបំរួលបរិយាកាស។ ឧទាហរណ៍ នៅក្នុងប្រទេសម៉ាឡេស៊ី ការប្រមូលកៅស៊ូជាប្រភពរកចំណូលសម្រាប់ជនជាតិដើមនៅខេត្តសារ៉ាវ៉ាក់ និងសាបា។ គេចោះយកជ័រកៅស៊ូនៅពេលដែលស្លឹកដើមកៅស៊ូធ្លាក់នៅកំឡុងខែសីហា និងកញ្ញា។ ដោយសារអាកាសធាតុប្រែប្រួលស្លឹកដើមកៅស៊ូធ្លាក់នៅដើមខែមករា ហើយហេតុដូច្នេះហើយជនជាតិដើមអាចប្រមូលជ័រកៅស៊ូបានតិច ដែលជាហេតុធ្វើឲ្យពួកគេរកប្រាក់ចំណូលមិនបានច្រើន។ ប្រភេទដើមឈើហូបផ្លែដទៃទៀត ដូចជា ធូរេន និងអងកាបាងនៅក្នុងខេត្តសារ៉ាវ៉ាក់ក៏ជាប្រភពរកប្រាក់ និងអាហារផងដែរ។ តែទោះបីជាយ៉ាងណាក៏ដោយការប្រមូលផលដំណាំដ៏ច្រើនពីដើមឈើទាំងនេះបានធ្លាក់ចុះជាខ្លាំង ដោយសារមានបំរែបំរួលអាកាសធាតុ ។

*ដកស្រង់ពី Galloway Mclean, 2009 ទំព័រ: 67*

ចំពោះប្រជាពលរដ្ឋជនជាតិដើមនៅក្នុងតំបន់អាស៊ាន បញ្ហាបំរែបំរួលបរិយាកាសជារឿងពិតរួចស្រេចទៅហើយ។ ការធ្លាក់ភ្លៀងមិនទៀងទាត់ និងគ្រោះរាំងស្ងួតដែលមានរយៈពេលកាន់តែយូរទៅៗ បានកាត់បន្ថយផលិតកម្មស្រែចំការ និងគុណភាពដី។ ព្យុះ និងទឹកជំនន់បានបំផ្លិចបំផ្លាញដំណាំ និងលំនៅឋានអស់ជាងច្រើន ហើយការកើនកំដៅទឹកសមុទ្របានធ្វើឲ្យប៉ះពាល់ដល់ផ្កាថ្ម ហើយហេតុដូច្នេះហើយបានគំរាមកំហែងដល់បរិមាណត្រី។ ហើយការកើនឡើងនៃនូវទឹកសមុទ្រ ដែលគេរំពឹងទុកនេះ និងបង្កគ្រោះគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់បណ្តារកោះតូចៗ។ ទោះបីជាប្រព័ន្ធជីវភាពខុសគ្នា និងមានភាពងើបឡើងវិញឆាប់រហ័សរបស់ជនជាតិដើមភាគតិចបានជួយឲ្យពួកគេអាចរស់នៅក្នុងស្ថានភាពដ៏លំបាកក៏ដោយ ក៏ល្បឿនដែលអាកាសធាតុកំពុងប្រែប្រួលបានធ្វើឲ្យសហគមន៍ជនជាតិដើមចេះសម្របខ្លួនទៅតាមស្ថានភាព។ លើសពីនេះទៀត បណ្តារសហគមន៍ជនជាតិដើមភាគតិចទូទាំងតំបន់អាស៊ានបានរាយការណ៍ពីអសន្តិសុខស្បៀងអាហារ និងទឹកដែលមានភាពធ្ងន់ធ្ងរឡើងៗ ការកើតនៃជម្ងឺដែលប្រើប្រាស់ទឹកមិនស្អាត និងជម្ងឺដែលចំលងដោយសត្វល្អិត និងបញ្ហាសត្វល្អិតចង្រៃដែលចេះតែកើនច្រើនឡើងៗ។ ដោយសារតែជនជាតិដើមភាគតិចមានជីវភាពក្រីក្រ និងត្រូវគេរើសអើងជាងគេបំផុតនៅលើសកលលោក ដូច្នេះពួកគេមានឱកាសតិចតួចណាស់ក្នុងការទទួលបានធនធាន ដើម្បីអាចសម្របខ្លួនទៅនឹងអាកាសធាតុ ។

ហេតុដូច្នេះហើយ ចំពោះជនជាតិដើមភាគតិចបំរែបំរួលបរិយាកាសមិនត្រឹមតែបង្ករការលំបាកដល់សេដ្ឋកិច្ចនោះទេ ប៉ុន្តែថែមទាំងបង្ករឲ្យមានការបំផ្លិចបំផ្លាញដល់ការ រស់នៅតាមបែប ប្រពៃណី និងវប្បធម៌រស់នៅប្រជាពលរដ្ឋជនជាតិដើម ដែលផ្សារភ្ជាប់ទៅនឹងធម្មជាតិ និងវដ្តកសិកម្ម។ តែទោះបីជាយ៉ាងណាក៏ដោយ បំរែបំរួលបរិយាកាសបង្ករឲ្យមានបញ្ហាដទៃច្រើនទៀតសម្រាប់ជនជាតិដើម ក្រៅពីធ្វើអោយការរស់នៅរបស់ពួកគេស្ថិតក្នុងស្ថានភាពលំបាក។

ផែនការជាច្រើនក្នុងចំណោមផែនការកាត់បន្ថយ និងសម្របសម្រួលដែលបង្កើតឡើងដោយរដ្ឋាភិបាល និងអង្គការអន្តរជាតិដើម្បីទប់ស្កាត់បំរែបំរួលបរិយាកាសដោយការពង្រីករោងចក្រផលិតប្រេងជីវសាស្ត្រការបង្កើតទំបន់ទឹកដែលស្ថិតក្រោមយន្តការអភិវឌ្ឍន៍ទឹកស្អាត ការចំរាញ់យកសារធាតុអ៊ុយរ៉ាញ៉ូម សម្រាប់រោងចក្រនុយក្លេអ៊ែរ ហើយនិងការដាក់បញ្ចូលព្រៃឈើរបស់ប្រជាពលរដ្ឋទៅក្នុងកម្មវិធី REDD ដោយគ្មានការយល់ព្រមជាញឹកញាប់រំលោភសិទ្ធិជនជាតិដើមដោយផ្ទាល់ ។







## ប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ីៈ រោងចក្រប្រេងដូងបានជំលៀសជនជាតិដើម ចេញពីដីជាប្រពៃណីរបស់ពួកគេ ។

ក្រុមអន្តររដ្ឋាភិបាលទទួលបន្ទុកខាងបញ្ហាបំរែបំរួលបរិយាកាស បានកំណត់ការផលិតនៃការ ចំរាញ់ប្រេងជីវសាស្ត្រលើកទី ២ ដែលនឹងត្រូវប្រើជាឥន្ទនៈថាជាមធ្យោបាយមួយផ្សេងទៀត ដែលបន្ធូរបន្ថយដល់បំរែបំរួលបរិយាកាស។ របាយការណ៍ពិសេសមួយ ដែលមានការវិភាគពី បញ្ហាមួយចំនួនដែលទាក់ទងនឹងការផលិតប្រេងជីវសាស្ត្រ (ជាពិសេសប្រេងដូង) ត្រូវគេធ្វើបទបង្ហាញនៅចំណុចទី ៦ ។ របាយការណ៍នោះបានគូសបញ្ជាក់ពីរបៀប ដែលជនជាតិដើមភាគ តិចនៅក្នុងប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី ដែលបានរងផលប៉ះពាល់ដោយការ ពង្រីករោងចក្រផលិតប្រេងដូង។ របាយការណ៍នេះត្រូវបានប្រើដោយ Aliansi Masyarakat Adat Nusantar ដែលហៅកាត់ថា ANMAN ដែលជាសហព័ន្ធជាតិនៃអង្គការប្រជាពលរដ្ឋ ជនជាតិ ដើមនៅក្នុងប្រទេសឥណ្ឌូនេស៊ី ហើយនឹងបណ្តារអង្គការដទៃទៀត ជាចំណុចបន្ថែមសំរាប់ ការបញ្ជូនឯកសាររបស់ពួកគេទៅឲ្យគណៈកម្មការលុបបំបាត់ការរើសអើងពូជសាសន៍ដែលហៅកាត់ថា CERD ។ ក្រោយមក CERD បានស្នើរឲ្យរដ្ឋាភិបាលឥណ្ឌូនេស៊ីឲ្យពិនិត្យសើរើច្បាប់នេះ ដែលជំរុញឲ្យមានការពង្រីករោងចក្រផលិតប្រេងដូង និងធានាឲ្យមានការគោរពសិទ្ធិ របស់ជនជាតិដើមភាគតិចឥណ្ឌូនេស៊ី។ ហេតុដូច្នេះ ហើយរដ្ឋាភិបាលបានពន្យាពេលផែនការពង្រីករោងចក្រផលិតប្រេងដូងនេះ។ ការផលិតប្រេងជីវសាស្ត្រនេះផ្តល់ នូវឱកាស និងបញ្ហា ប្រឈម។ បើពិចារណាមើលអំពីនិន្នាការសម្រាប់ផលិតកម្ម ឧស្សាហ៍កម្មនៅក្នុងចំណោម ជន ជាតិដើមភាគតិចជាច្រើន ប្រេងជីវសាស្ត្រអាចផ្តល់នូវឱកាស សេដ្ឋកិច្ចដ៏អស្ចារ្យ។ តែទោះបីជា យ៉ាងណាក៏ដោយ ការផលិតប្រេងជីវសាស្ត្រអាចទូទាត់ផល ប្រយោជន៍ដ៏ច្រើនពីការបំភាយ បរិ យាកាស នៅពេលដែលព្រៃឈើត្រូវកាប់ឆ្ការសំរាប់ការផលិត ប្រេងជីវសាស្ត្រដូចជាប្រេងដូង។ ការកាប់ឆ្ការព្រៃ ដើម្បីផលិតប្រេងជីវសាស្ត្រក៏អាចបណ្តាល ឲ្យមានការរំលោភបំពានសិទ្ធិកាន់កាប់ ដីធ្លីរបស់ជនជាតិដើមភាគតិច ដូចដែលបានកើតឡើងនៅប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី។

*ដកស្រង់ចេញពី Galloway Mclean ឆ្នាំ ២០០៩ ទំព័រ ៦៧*



ទំនាក់ទំនងរវាងបំរែបំរួលបរិយាកាស និងសិទ្ធិមនុស្ស ត្រូវបានគេគូសបញ្ជាក់នៅក្នុងរបាយការណ៍នាពេលថ្មីៗនេះរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស។[៤] របាយការណ៍ ដែលអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្សនៅឆ្នាំ ២០០៩ បានគូសបញ្ជាក់ពីការជាប់ទាក់ទងគ្នាផ្សេងៗទៀតនៃបំរែបំរួលបរិយាកាស និងវិធានការបន្ធូរបន្ថយសំរាប់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋជនជាតិដើម និងបណ្តាក្រុមដែលងាយរងគ្រោះដទៃទៀត។ របាយការណ៍នេះសន្និដ្ឋានថា បំរែបំរួលបរិយាកាស និងវិធានការបន្ធូរបន្ថយដែលបានអនុម័តដទៃទៀត មិនត្រឹមតែគំរាមកំហែងដល់ការបំផ្លិចបំផ្លាញដល់ការរស់នៅរបស់ជនជាតិដើមនោះទេ ប៉ុន្តែថែមទាំងបំផ្លិចបំផ្លាញដល់អត្តសញ្ញាណវប្បធម៌ និងសង្គមរបស់ពួកគេ ហើយជាចុងក្រោយបំផ្លិចបំផ្លាញសិទ្ធិក្នុងការសំរេចចិត្តរបស់ពួកគេ។ ដោយសារតែពួកគេស្ទើរតែមិនបានចូលរួមចំណែកអ្វីបានទាំងអស់ដល់បុព្វហេតុដែលនាំឲ្យមានការកើនឡើងកំដៅផែនដី ដូច្នេះហើយជនជាតិដើមភាគតិចដែលស្ថិតក្នុងចំណោមអ្នកដែលរងផលប៉ះពាល់ខ្លាំងបំផុត ។



## ប្រទេសមីយ៉ាន់ម៉ា កំលាំងពលកម្មសំរាប់រោងចក្រ Jatropha នៅក្នុងរដ្ឋ Chin

នៅក្នុងប្រទេសមីយ៉ាន់ម៉ា រដ្ឋាភិបាលបានជំរុញឲ្យមានរោងចក្រ Jatropha នៅក្នុងរដ្ឋ Chin ។ កំលាំងពលកម្មត្រូវបានគេប្រើប្រាស់ ដើម្បីសាងសង់រោងចក្រទាំងនេះ កងកំលាំងត្រូវគេបញ្ជា ឲ្យទៅរឹបអូសយកដីជនជាតិដើមភាគតិច ហើយមានការបាត់បង់ប្រាក់ចំណូលសំរាប់មនុស្សទាំងនេះ ពីព្រោះគេត្រូវគេបង្ខំឲ្យទិញកូនរុក្ខជាតិ Jatropha ។

*(ដកស្រង់ចេញពី Malloway Melean ឆ្នាំ ២០០៩ ទំព័រ ៦៧)*

# ការឆ្លើយតបរបស់តំបន់អាស៊ាន ចំពោះបំរែបំរួលបរិយាកាស

អាស៊ានបានចូលរួមក្នុងការចរចារ អន្តរជាតិស្តីពីបំរែបំរួលបរិយាកាស ហើយ នឹងប្រធាននៃប្រទេសជាសមាជិករបស់ខ្លួន បានបញ្ជាក់ពីការប្តេជ្ញារបស់ពួកគេ ដែល ដើរតួយ៉ាងសកម្មក្នុងការដោះស្រាយបំរែ បំរួលបរិយាកាស។ ការប្តេជ្ញាចិត្តនេះបាន បញ្ជាក់នៅក្នុងសេចក្តីប្រកាសរបស់ពួកគេ នៅឯសន្និសិទ្ធិបំរែបំរួលអាកាសធាតុរបស់ អង្គការសហប្រជាជាតិនៅកោះ Bali នៅឆ្នាំ ២០០៧ ហើយនៅក្នុងទីក្រុង Copenhagen នៅឆ្នាំ ២០០៩ ។ ការប្តេជ្ញាចិត្តនេះ ក៏ត្រូវ បានបញ្ជាក់ក្នុងសេចក្តីថ្លែងការមេដឹកនាំ អាស៊ានស្តីពីការឆ្លើយតបរួម ចំពោះបំរែបំរួល បរិយាកាសដែលបានប្រកាសនៅកិច្ចប្រជុំ កំពូលអាស៊ានលើកទី ១៦ នៅទីក្រុង ហាណូយ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០ ។

ទស្សនៈវិស័យឆ្នាំ ២០២០ របស់អាស៊ាន អំពាវនាវឲ្យមានអាស៊ានស្អាត និងស្រស់ បំព្រង ដែលធានាឲ្យមានការការពារបរិស្ថាន ការប្រើប្រាស់ធនធានធម្មជាតិដែលមាន លក្ខណៈចេរភាព និងធានាឲ្យប្រជាជនមាន ជីវភាពល្អប្រសើរ។ តែទោះបីជាយ៉ាងណា ក៏ដោយអាស៊ានមិនមានគោលនយោបាយ ស្តីអំពីបំរែបំរួលបរិយាកាសច្បាស់លាស់ នោះទេ។ អាស៊ានកំពុងដោះស្រាយបំរែបំរួល បរិយាកាសតាមរយៈក្របខណ្ឌនៃការបង្កើត សហគមន៍អាស៊ាន ដែលជាផែនទីផ្លូវសំរាប់ សហគមន៍អាស៊ានឆ្នាំ ២០០៩-២០១៥ ដែលមេដឹកនាំអាស៊ានបានអនុម័តភ្លាម បន្ទាប់ពីធម្មនុញ្ញអាស៊ានចូលជាធរមាននៅ ខែធ្នូ ឆ្នាំ ២០០៨ ។ បំរែបំរួលបរិយាកាស ជាប់ពាក់ព័ន្ធនឹងបរិបទនៃការអភិវឌ្ឍន៍ដែល មានចេរភាព និងយុទ្ធសាស្ត្រ និងវិធាន ការដែលបានគូស បញ្ជាក់នៅក្នុងផែនការ មេចំនួន ៣ គឺមានដូចជា ផែនការមេ សហគមន៍ សង្គម វប្បធម៌ អាស៊ាន ផែនការមេសហគមន៍សេដ្ឋកិច្ចអាស៊ាន និងផែនការមេ សហគមន៍ សុវត្ថិភាព នយោបាយអាស៊ាន។

ផែនការមេសំរាប់ សហគមន៍ សង្គម វប្បធម៌ អាស៊ាន ដែលហៅកាត់ថា ផែនការ មេ ASCC ឆ្នាំ ២០០៩-២០១៥ នៅត្រង់ ចំណុច D ដែលធានាឲ្យមានចេរភាព បរិស្ថានដែលបានកំណត់ផែនការជាអាទិភាព ចំនួន ១០ នៃសារៈសំខាន់តំបន់សំរាប់កិច្ច-សហប្រតិបត្តិការបរិស្ថាននៅក្នុងចំណោម សមាជិកអាស៊ាន។ ផ្នែកអាទិភាពទី ១០ គឺឆ្លើយតបទៅនឹងបំរែបំរួលបរិយាកាស និង ដោះស្រាយផលប៉ះពាល់ ហើយវត្ថុបំណង ដែលជាយុទ្ធសាស្ត្ររបស់អាស៊ានបានចែង ថាៈ ជំរុញឲ្យមានកិច្ចសហប្រតិបត្តិការ ថ្នាក់តំបន់ និងអន្តរជាតិ និងដោះស្រាយ បញ្ហាបំរែបំរួលបរិយាកាស និងផលប៉ះពាល់ មកលើការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច សុខភាព និងបរិស្ថាន នៅក្នុងបណ្តាប្រទេស ជាសមាជិកអាស៊ានតាមរយៈការចាត់វិធាន ការបន្ធូរបន្ថយ និងសំរបសំរួលដោយពឹងផ្អែក លើគោលការណ៍គ្រឹះនៃសមភាពភាពដែល អាចបត់បែនបាននឹងមានលក្ខណៈរួម ប៉ុន្តែ ការទទួលខុសត្រូវ និងសមត្ថភាពខុសគ្នា និងឆ្លុះបញ្ចាំងពីស្ថានភាពសង្គម និង សេដ្ឋកិច្ចខុសៗគ្នា។[៥]

អនុលោមតាមផ្នែកជាអាទិភាពនេះ ផែនការមេនេះ បានកំណត់សកម្មភាពជា អាទិភាព ចំនួន ១១ ដែលសំដៅៈ

- ការបង្កើនកិច្ចខំប្រឹងប្រែងក្នុងចំណោម សមាជិកអាស៊ាន
- ការលើកកំពស់ និងការសំរួលដល់ការ ផ្លាស់ប្តូរចំណេះដឹងបទពិសោធន៍ និង បច្ចេកទេស
- កិច្ចសហប្រតិបត្តិការអន្តរជាតិស្តីពី សកម្មភាពដែលទាក់ទងនឹងការអភិរក្ស ព្រៃឈើ (ការដាំដើមឈើឡើងវិញ) និង ការកាត់បន្ថយការបំផ្លិចបំផ្លាញព្រៃឈើ
- ការធ្វើយុទ្ធសាស្ត្រតំបន់ ស្តីពីការសំរប សំរួល
- កិច្ចសហប្រតិបត្តិការដោះស្រាយ គ្រោះថ្នាក់
- ការត្រួតពិនិត្យ និងការសាវជ្រាវស្តីពីការ បំរែបំរួលបរិយាកាស
- ការលើកកំពស់ការយល់ដឹងសាធារណៈ
- ការជំរុញឲ្យមានការចូលរួមពីរដ្ឋាភិបាល មូលដ្ឋាន វិស័យឯកជន អង្គការក្រៅរដ្ឋា-ភិបាល និងសហគមន៍ ដើម្បីដោះស្រាយ ផលប៉ះពាល់បំរែបំរួលបរិយាកាស [៦]

អាស៊ានបានបង្កើតក្រុមការងារទទួល បន្ទុកការងារបំរែបំរួលបរិយាកាសដែល ហៅកាត់ថា AWGCC និងផែនការបំរែបំរួល បរិយាកាសអាស៊ាន ដែលហៅកាត់ថា ACCI ជាវេទិកាប្រឹក្សាយោបល់តំបន់។ តែទោះបីយ៉ាងណាក៏ដោយស្ថាប័ន ២ នេះ







គ្មានសិទ្ធិអំណាច ដើម្បីជួយពួកគេសំរេចវត្ថុបំណងនោះទេ ដូចជា ការពង្រឹងកិច្ច-សហប្រតិបត្តិការជាមួយសមាជិករបស់ខ្លួន នឹងការពង្រឹងគោលជំហរអាស៊ានជាប្លុកនៅក្នុង UNFCCC ។

កំឡុងពេលសន្និសិទ្ធិរបស់ UNFCCC មុននៃភាគីអាស៊ាន (COP ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០ នៅទីក្រុង Cancum ប្រទេសម៉ិចស៊ិកូ) តាមរយៈប្រធានអាស៊ាននៅពេលគឺប្រទេសវៀតណាម ដែលបានបញ្ជាក់ពីការប្តេជ្ញាសារជាថ្មី ដល់វិធីសារ Kyoto ហើយបានអំពាវនាវឲ្យមានលទ្ធផលរួមដែលមានប្រសិទ្ធិភាពដែលពន្យល់ពីការទទួលខុសត្រូវផ្សេងៗពីគ្នា ។[៧]

តែទោះបីជាមានការបញ្ជាក់ជាដដែលៗពីការប្តេជ្ញាចិត្ត ដើម្បីដោះស្រាយបញ្ហាបំរែបំរួលបរិយាកាស និងការអំពាវនាវឲ្យមានកិច្ចសហប្រតិបត្តិការក៏ដោយ អាស៊ានមិនទាន់ជាស្ថាប័ន ដែលមានការឯកភាពគ្នាក្នុងការដោះស្រាយបញ្ហាបំរែបំរួលបរិយាកាសនោះទេ។ អាស៊ានត្រូវបានរិះគន់ដោយសារខ្វះឆន្ទៈនយោបាយក្នុងការអនុវត្តសេចក្តីប្រកាសរបស់ខ្លួន។ នៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកចុងក្រោយ កាលពីខែឧសភា ឆ្នាំ ២០១១ នៅទីក្រុងចាកាតា បញ្ហាបំរែបំរួលបរិយាកាសមិនត្រូវបានដាក់បញ្ចូលក្នុងរបៀបវារៈនៃកិច្ចប្រជុំកំពូលអាស៊ាននោះទេ។ សកម្មភាពនេះ បានបង្ហាញឲ្យឃើញថា បញ្ហាបំរែបំរួលបរិយាកាសមិនត្រូវគេផ្តល់អាទិភាពនោះទេ ហើយការខ្វះឆន្ទៈនយោបាយដោះស្រាយជាអ្វីដែលមនុស្សជាច្រើនចាត់ទុកថា ជាគ្រោះគំរាមកំហែងដ៏ធំបំផុតដល់ជីវិត និងសុខមាលភាពរបស់មនុស្សច្រើនជាង ៦០០លាននាក់ដែលកំពុងរស់នៅក្នុងតំបន់អាស៊ាននោះ ។



## អាស៊ាន និងកម្មវិធី REDD+

គេបានប៉ាន់ប្រមាណថាឆ្នាំ ២០០០ អាស៊ីអាគ្នេយ៍បានបង្ករអោយមានការបំភាយឧស្ម័ន ផ្ទះកញ្ចក់ពិភពលោកចំនួន ១២% ហើយគេបានប៉ាន់ប្រមាណទៀតថា ៧៥% នៃការបំភាយឧស្ម័ននេះបណ្តាលមកពីការផ្លាស់ប្តូរការប្រើប្រាស់ដី ដែលរាប់បញ្ចូលទាំងការកាប់បំផ្លាញព្រៃឈើ។[៨] ដូច្នោះហើយការកាត់បន្ថយបំភាយឧស្ម័នពីការកាប់



បំផ្លាញព្រៃឈើនឹងត្រូវចាត់ទុកជាអាទិភាពក្នុងវិធានការកាត់បន្ថយបំរែបំរួលបរិយាកាសនៃប្រទេសអាស៊ាន។ សេចក្តីថ្លែងការណ៍ចុះនៅ ខែមេសា ឆ្នាំ២០១២ ស្តីពីការឆ្លើយតបរួមចំពោះបំរែបំរួលបរិយាកាសរបស់មេដឹកនាំអាស៊ាន បានទទួលស្គាល់ពីសារសំខាន់នៃការគ្រប់គ្រងព្រៃឈើដែលមានលក្ខណៈចីរភាពនៅក្នុងអាស៊ានដែលនឹងរួមចំណែកដ៏សំខាន់ដល់កិច្ចខិតខំប្រឹងប្រែងអន្តរជាតិជំរុញឲ្យមានចីរភាពបរិស្ថាន ហើយកាត់បន្ថយផលប៉ះពាល់បំរែបំរួលបរិយាកាស។ របាយការណ៍នេះក៏បានបញ្ជាក់សារជាថ្មីផងដែរថា កិច្ចព្រមព្រៀងស្តីពីការអនុវត្តដ៏មានប្រសិទ្ធិភាពនៃការកាត់បន្ថយការបំភាយឧស្ម័ន ដែលបណ្តាលមកពីការកាប់បំផ្លាញព្រៃឈើ បូករួមនឹងយន្តការនានា គឺមានសារសំខាន់ខ្លាំងណាស់សំរាប់ការចូលរួមចំណែក ពីបណ្តារប្រទេសជាសមាជិកអាស៊ាន ដើម្បីកាត់បន្ថយការបំភាយឧស្ម័ន ហើយនឹងផ្តល់ឱកាសដល់ការជំរុញឲ្យមានការអភិវឌ្ឍន៍ជីវសាស្រ្តចំរុះ និងការប្រើប្រាស់ធនធានធម្មជាតិដែលមានលក្ខណៈចីរភាព និងការគាំពារជីវភាពរស់នៅរស់សហគមន៍មូលដ្ឋាន។[៩] វិធានការទី ៤ នៃចំណុច D ជាអាទិភាពនៅក្នុងផែនការមេ ក៏បានបញ្ជាក់យ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់អាស៊ានចំពោះកម្មវិធី REDD ។ ផែនការមេនេះលើកឡើងថា វិធានការនេះសំដៅជំរុញឲ្យសហគមន៍អន្តរជាតិ ឲ្យចូលរួមចំណែកដល់ការខិតខំប្រឹងប្រែងអាស៊ាន ក្នុងការដាំដើមឈើឡើងវិញ និងកាត់បន្ថយការកាប់បំផ្លាញព្រៃឈើ។[១០]

អាស៊ានដែលពឹងផ្អែកលើផែនការចំនួន ៣ របស់ខ្លួន ហើយក្របខណ្ឌជាយុទ្ធសាស្រ្តសមូហរណកម្ម អាស៊ានបានចេញផ្សាយពីក្របខណ្ឌពហុវិស័យ ដែលមានកសិកម្ម និងនេសាទ សំដៅឲ្យមានសុវត្ថិភាពស្បៀងអាហារ (AFCC-FS) នៅឆ្នាំ ២០០៩។ គោលដៅរបស់ AFCC-FC គឺដើម្បីចូលរួមចំណែកដល់សន្តិសុខ ស្បៀងអាហារ តាមរយៈការប្រើប្រាស់ ដី ទឹក និងធនធានជលជាតិប្រកបដោយប្រសិទ្ធិភាព និងមានលក្ខណៈចីរភាព ដោយកាត់បន្ថយគ្រោះហានិភ័យ និងផលប៉ះពាល់ដែលបណ្តាលឲ្យមានបំរែបំរួលបរិយាកាស ។

វត្ថុបំណងនេះមានដូចខាងក្រោម៖

1. ការសំរួលដល់ការអភិវឌ្ឍន៍នៃយុទ្ធសាស្រ្តសំរបសំរួល និងបន្ធូរបន្ថយ
2. កិច្ចសហប្រតិបត្តិការស្តីអំពីការអនុវត្តវិធានការសំរបសំរួល និងបន្ធូរបន្ថយដែលត្រូវបានធ្វើសមូហរណកម្ម [១១]

ខណៈពេលដែលផែនការមេ ASCC នេះសំដៅទៅលើការកាប់បំផ្លាញព្រៃឈើ ដែលស្ថិតក្រោមវិធានការទី ៤ ជាអាទិភាព REDD មិនជាប់ពាក់ព័ន្ធជាមួយ AFCC-FC នោះទេ។ តែទោះបីជាយ៉ាងណាក៏ដោយ បណ្តាប្រទេសអាស៊ានជាច្រើនបានចូលរួមកម្មវិធី REDD [១២] រួចជាស្រេចទៅហើយ តាមរយៈកម្មវិធី អង្គការពហុភាគី ដែលមានដូចជា UN-REDD FCPF និងកម្មវិធីវិនិយោគព្រៃឈើ (FIP) តាមរយៈគំរោងទ្វេភាគី ដែលជាកម្មវិធីរបស់ប្រទេសរបស់ពួកគេផ្ទាល់ រឺក៏តាមរយៈផែនការតូចនៃភ្នាក់ងារអភិរក្ស និងស្ថាប័នឯកជនអន្តរជាតិក្នុងកម្មវិធី REDD ។ មានប្រទេសជាសមាជិកអាស៊ានចំនួន ៧ ក្នុងចំណោមប្រទេសជាសមាជិកអាស៊ានទាំង ១០ ចូលរួមក្នុងកម្មវិធី REDD យ៉ាងហោចណាស់មួយក្នុងចំនួនកម្មវិធីទាំង ៣ ដូចខាងក្រោម៖

- ធនាគារពិភពលោក FCPF មានដូចជា ប្រទេសកម្ពុជា ឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមាណិតឡាវ មីយ៉ាន់ម៉ា ថៃ និង វៀតណាម។
- កម្មវិធីវិនិយោគព្រៃឈើរបស់ធនាគារពិភពលោក (FIP) ដែលមានប្រទេសឥណ្ឌូនេស៊ី និងសាធារណៈរដ្ឋប្រជាមានិតឡាវ
- UN-REDD មានប្រទេសកម្ពុជា ឥណ្ឌូនេស៊ី ហ្វីលីពីន និងវៀតណាម ។

ប្រទេសម៉ាឡេស៊ី មិនមែនជាផ្អែកនៃកម្មវិធី REDD ជាសកលនោះទេ ប៉ុន្តែប្រទេសនេះមានកម្មវិធី REDD របស់ជាតិ ហើយទទួលមូលនិធិទ្វេភាគី ពីប្រទេសជប៉ុន។ ប្រទេសមីយ៉ាន់ម៉ា បានចាប់ផ្តើមកម្មវិធី REDD ជាមួយ UN-REDD នៅក្នុងឆ្នាំ ២០១១។ ប្រទេសមីយ៉ាន់ម៉ាក៏បានទទួលជំនួយពីប្រទេសជប៉ុនដែរ ។

ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពរបស់ GEF និងកម្មវិធី REDD+ (GEF SFM/REDD+) មានវិសាលភាពទូលំទូលាយបន្ថែមចំពោះ REDD+ វាផ្តោត











ទៅការអភិរក្សជីវចម្រុះ និងការដោះស្រាយការរិចរិលដីក្នុងពេលជាមួយគ្នា ។ ដោយសារ GEF មានការគ្រប់ដណ្តប់លើបណ្តាប្រទេសកំពុងអភិវឌ្ឍន៍លើសកលលោក ភាគច្រើនគឺបណ្តាប្រទេសសមាជិកអាស៊ាន (ASEAN) ដែលអាចចូលរួមតាមរយៈមធ្យោបាយមួយបែប ឬផ្សេងទៀតនៅក្នុង SFM/REDD+ ។

អាស៊ានមិនទាន់មានគោលនយោបាយច្បាស់ទៅលើ REDD+ នៅឡើយទេ ប៉ុន្តែក៏មានយន្តការរួចរាល់ហើយក្នុងតំបន់ ដើម្បីផ្តល់ឱកាសសម្រាប់អាស៊ាន ដើម្បីទទួលយកនូវតួនាទីដ៏សំខាន់ ដូចជាតាមរយៈការសម្របសម្រួលការផ្តួចផ្តើមសមាជិករបស់ខ្លួន និងការសម្របសម្រួលការផ្លាស់ប្តូរបទពិសោធន៍ដែលបានទទួលក្នុងតំបន់អំពី REDD+ ។

ជំហានចាប់ផ្តើមក្នុងទិសដៅនេះ បានកើតឡើងរួចហើយ ដោយមានការប្រារព្ធសន្និសិទស្តីពី "ព្រៃឈើសម្រាប់មនុស្ស-តួនាទីការគ្រប់គ្រងព្រៃឈើសង្គមស្តីពី REDD+ និងការអភិរក្សព្រៃឈើ" ដែលបានរៀបចំដោយបណ្តាញការពារព្រៃឈើសង្គមអាស៊ាន (ASFS) ។ ASFN មានសក្តានុពល ដើម្បីដើរតួនាទីដឹកនាំក្នុងការសម្របសម្រួលការផ្លាស់ប្តូរបទពិសោធន៍ និងជួយផ្សព្វផ្សាយការទំនាក់ទំនងពីសហគមន៍ក្នុងការគ្រប់គ្រងព្រៃឈើ ហើយ REDD+ មិនមែនគ្រាន់តែមានក្នុងចំណោមប្រទេសសមាជិកអាស៊ានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានក្នុងរង្វង់នៃការផ្តួចផ្តើមរបស់ REDD+ លក្ខណៈអន្តរជាតិ ដូចជាៈ FCPF, FIP និង UN-REDD ។ល។

## REDD+ និងជនជាតិដើមភាគតិច

នៅក្នុងតំបន់អាស៊ាន គេប៉ាន់ប្រមាណថាមានប្រជាជនប្រមាណ៦០លាននាក់ (២០% នៃចំនួនប្រជាជនជនបទ ៣០០លាននាក់) គឺពឹងផ្អែកលើធនធានព្រៃឈើយ៉ាងខ្លាំងសម្រាប់ជីវភាពរបស់ពួកគេ ។[១៣] តួលេខក៏អាចកើនឡើងខ្ពស់ជាងនេះ ដោយសារចំនួនប្រជាជនសរុបនៃជនជាតិដើមភាគតិចអាស៊ានតែមួយ ផ្អែកស្ទើរតែស្មើ ឬច្រើនជាង ១០០លាននាក់ទៅហើយ ។ ជនជាតិដើមភាគតិចជាច្រើនរស់នៅតាមតំបន់ខ្ពង់រាប និងតំបន់ដាច់ស្រយាលនៅតែពឹងផ្អែកទៅលើព្រៃឈើ ។ សម្រាប់ពួកគេ ព្រៃឈើមានសារៈសំខាន់សម្រាប់ការរស់នៅដោយសារភាគច្រើននៃពួកគេពឹងផ្អែកលើព្រៃឈើសម្រាប់ជីវភាពរបស់ពួកគេ វាផ្តល់នូវធនធានជាបន្តបន្ទាប់ និងជាប្រភពចំណូលដ៏សំខាន់ផងដែរ ។ ព្រៃឈើមិនត្រឹមតែជាមូលដ្ឋាននៃជីវភាពរបស់ពួកគេប៉ុណ្ណោះទេ តែវាក៏ជាចំណែកនៃការគោរពទៅលើជំនឿវប្បធម៌របស់ពួកគេផងដែរ ។

តំបន់អាស៊ីអាគ្នេយ៍ គឺជាតំបន់មួយដែលមានភាពចម្រុះវប្បធម៌ច្រើនជាងគេក្នុងពិភពលោក។ គេប៉ាន់ប្រមាណថា រវាង ៤,០០០ និង ៥,០០០ នៃភាសានិយាយលើពិភពលោក ពី៥,០០០ ទៅ ៧,០០០ ភាសា គឺជាភាសារបស់ជនជាតិដើមភាគតិច។ នៅ Papau New Guinea និងប្រទេសឥណ្ឌូណេស៊ី មានការប៉ាន់ស្មានមួយថា គេនិយាយភាសាខុសប្លែកគ្នារហូតដល់ទៅ ១,៥០០ ភាសា ។ គេបានរកឃើញថានៅអាស៊ី និងប៉ាស៊ីភិច មានការបាត់បង់ភាសាលើសពី ៦១% ហើយភាគច្រើនជាភាសាដែលប្រើដោយពួកជនជាតិដើមភាគតិច ។

ប្រសិនបើការប្រើប្រាស់ភាសា ត្រូវបានគេប្រើជាសូចនាករ សម្រាប់ជាចំណុចខ្លាំងនៃការកំណត់អត្តសញ្ញាណវប្បធម៌របស់ប្រជាជន ការពិតគឺថា មានភាសាជាច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍ស្ថិតក្រោមការគំរាមកំហែង ដែលធ្វើឲ្យប្រជាជនទាំងនេះកំពុងទទួលរងនូវសំពាធផងដែរ ។

អង្គការសហប្រជាជាតិទទួលស្គាល់ថា ចំពោះជនជាតិដើមភាគតិច ដើម្បីសង្គ្រោះជីវិត និងរស់នៅឲ្យមានសេចក្តីថ្លៃថ្នូរជាមនុស្ស សិទ្ធិសមូភាពភាពរបស់ពួកគេចាំបាច់ត្រូវទទួលស្គាល់ និងការពារ ។ ដូច្នេះក្នុងឆ្នាំ២០០៧ សភាវិសាមញ្ញ សហប្រជាជាតិ បានអនុម័តសេចក្តីប្រកាសសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ។ ក្រៅពីនេះក៏មានឯកសារច្បាប់អន្តរជាតិសំខាន់ៗផ្សេងទៀត ការពារសិទ្ធិជនជាតិដើមភាគតិច ដូចជាៈ អនុសញ្ញា ១៦៩ របស់ ILO, អនុសញ្ញាស្តីពីការលុបបំបាត់ចោលរាល់ទម្រង់នៃការរើសអើងជាតិសាសន៍, កិច្ចព្រមព្រៀងស្តីពីសិទ្ធិនយោបាយ និងសិទ្ធិបុគ្គល (Civil right) ឬកិច្ចព្រមព្រៀងស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ។



បណ្ដាប្រទេសអាស៊ានភាគច្រើនបានចុះហត្ថលេខាទាំងអស់ ឬក៏យ៉ាងហោចណាស់ក៏បានចុះហត្ថលេខាមួយចំនួនដែរ និងមានអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិសំខាន់ៗផ្សេងទៀត ហើយភាគច្រើនបានបោះឆ្នោតគាំទ្ររបស់ UNDRIP ។

បច្ចុប្បន្ននេះ វាបង្កើតឲ្យមានការទទួលស្គាល់ និងការពារសិទ្ធិចំពោះការកាន់កាប់ដីធ្លី និងធនធានរបស់ពួកគេកាន់តែល្អប្រសើរដែលជាល័ក្ខខ័ណ្ឌមុន សម្រាប់ជនជាតិដើមភាគតិចយ៉ាងសំខាន់បំផុតដើម្បីថែរក្សា និងធ្វើឲ្យកេរ៏តំណែលវប្បធម៌ដ៏សម្បូរបែបរបស់ពួកគេ នៅបន្តដល់អ្នកជំនាន់ក្រោយរបស់ពួកគេ ។ ក្នុងតំបន់អាស៊ាន កន្លែងដែលជនជាតិដើមភាគតិចភាគច្រើនរស់នៅ អាស្រ័យផលទៅលើព្រៃឈើ នេះមានន័យថាសិទ្ធិរបស់ពួកគេទៅលើព្រៃឈើ ចាំបាច់ត្រូវទទួលស្គាល់ ។

ការទទួលស្គាល់សិទ្ធិព្រៃឈើរបស់ជនជាតិដើមភាគតិច និងសហគមន៍ព្រៃឈើផ្សេងៗទៀត វាធ្វើឲ្យមានស្ថានការណ៍ឈ្នះ-ឈ្នះ: ការគ្រប់គ្រងព្រៃឈើសហគមន៍ ជួយអភិរក្សព្រៃឈើតំបន់អាស៊ីអាគ្នេយ៍ ស្របពេលជាមួយគ្នាដែរ ដើម្បីចូលរួមការពារសិទ្ធសមូភាពរបស់ជនជាតិដើមភាគតិច ។ មួយវិញទៀត ជួយថែរក្សាកេរ៏តំណែលវប្បធម៌ដ៏សម្បូរបែបនៃអាស៊ានផងដែរ ។

UNFCCC ក៏បានទទួលស្គាល់ផងដែរនូវសេចក្ដីត្រូវការ ដើម្បីការពារសិទ្ធិជនជាតិដើមភាគតិចនិងសហគមន៍ព្រៃឈើ និងដើម្បីផ្សព្វផ្សាយការចូលរួមរបស់ពួកគេទៅលើ REDD+ ឲ្យបានសកម្ម ។ អត្ថបទពង្រៀងសេចក្ដីសម្រេចស្ដីពី REDD+ របស់ក្រុមការងារ Ad Hoc នៃ UNFCCC ស្ដីពីសកម្មភាពសហប្រតិបត្តិការរយៈវែង បានអនុម័តនៅក្នុងសន្និសិទបណ្ដាភាគីលើកទី ១៥ របស់ UNFCCC ក្នុងទីក្រុង Cancun ប្រទេសម៉ិចស៊ិកូ សំដៅឲ្យបណ្ដាប្រទេសផ្សេងៗទៀត ចាំបាច់ត្រូវដោះស្រាយបញ្ហាសិទ្ធិកាន់កាប់ដីធ្លី និងធានា "ការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធិភាពនៃអ្នកពាក់ព័ន្ធក្នុងចំណោមជនជាតិដើមភាគតិច និងសហគមន៍ក្នុងតំបន់" (ចែងក្នុងមាត្រា ៧២)។ [១៥] កថាខ័ណ្ឌទី២ ឧបសម្ព័ន្ធ I[១៦] អំពាវនាវឲ្យបណ្ដាភាគី ដើម្បីជួយផ្សព្វផ្សាយ និងគាំទ្រការការពារទាំងប្រាំពីរចំណុច, ដែលមានបីចំណុចពិសេស ហើយពាក់ព័ន្ធដល់ជនជាតិដើមភាគតិចច្បាស់នោះគឺ:

(c.) គោរពចំពោះការយល់ដឹង និងសិទ្ធិរបស់ជនជាតិដើមភាគតិច និងសមាជិកសហគមន៍ក្នុងតំបន់ដោយទទួលខុសត្រូវកាតូកិច្ចអន្តរជាតិដែលពាក់ព័ន្ធព្រឹត្តការណ៍ក្នុងប្រទេស និងច្បាប់នានា យល់ដឹងថាកិច្ចប្រជុំវិសាមញ្ញសហប្រជាជាតិបានអនុម័តនូវសេចក្ដីប្រកាសសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើមភាគតិច ។

(d.) ការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធិភាពរបស់អ្នកពាក់ព័ន្ធ ពិសេសជនជាតិដើមភាគតិច និងសហគមន៍ក្នុងតំបន់ឆ្លើយតបទៅនឹងសកម្មភាពនានា ដូចមានចែងក្នុងកថាខ័ណ្ឌ៧០ និង៧២ នៃសេចក្ដីសម្រេចនេះ ។

(e.) សកម្មភាពមិនមានការផ្លាស់ប្ដូរទៅនឹងការអភិរក្សព្រៃធម្មជាតិ និងជីវៈចម្រុះ កំពុងធានាថា សកម្មភាពឆ្លើយតបដូចក្នុងកថាខណ្ឌ ៧០ នៃសេចក្ដីសម្រេចនេះ មិនត្រូវបានប្រើ ធ្វើឲ្យមានការប្រែប្រួលព្រៃធម្មជាតិ ប៉ុន្តែតែជួយ លើកទឹកចិត្តការថែរក្សា និងអភិរក្សព្រៃធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី និងបង្កើនផលប្រយោជន៍សង្គម និងបរិស្ថានផ្សេងៗទៀត ។[១៦]

ព័ត៌មានខាងចុងចំពោះការការពារ (ក្នុងចំណុច e) បង្ហាញថា" ការទទួលខុសត្រូវចាំបាច់សម្រាប់ជីវភាពជនជាតិដើមភាគតិច និងសហគមន៍ក្នុងតំបន់ និងការពឹងផ្អែកគ្នាទៅវិញទៅមករបស់ពួកគេទៅលើព្រៃឈើក្នុងបណ្ដាប្រទេសជាច្រើន ប្រកបដោយនិរន្តរភាព បានបង្ហាញនៅក្នុងសេចក្ដីប្រកាសសហប្រជាជាតិស្ដីពីសិទ្ធិជនជាតិដើមភាគតិច ក៏ដូចជានៅក្នុងទិវាមាតាពិភពលោកអន្តរជាតិ ។[១៧]

ការការពារ បានដាក់បញ្ចូលក្នុងអត្ថបទពង្រាងសេចក្ដីសម្រេចរបស់ AWG-LCA ដែលស្នើសុំផ្ដល់ការណែនាំ និងប្រើប្រាស់ជាឯកសារគោលមួយសម្រាប់ការចាប់ផ្ដើមការការពារ ដែលមាននៅក្នុងកម្មវិធី REDD+ ថ្នាក់ជាតិ និងអន្តរជាតិ ។ ពួកគេកំពុងតែអនុវត្តន៍ការការពារបរិស្ថាន និងសង្គមដែលមានកន្លងមក ហើយកំពុងប្រើប្រាស់ជាគោលមួយដើម្បីបន្សាំការការពារដែលមាន ហើយបង្កើតនូវការការពារថ្មីដែលស្ថិតនៅក្នុងការផ្ដួចផ្ដើមរបស់ REDD+ ។

ការចូលរួមដោយសេរី មានពត៌មានគ្រប់គ្រាន់ និងការឯកភាពជាមុន របស់ជនជាតិដើមភាគតិច បច្ចុប្បន្ននេះ កំពុងត្រូវបានគេទទួលស្គាល់យ៉ាងច្រើន ថាជាគោលការណ៍គន្លឹះមួយក្នុងការអនុវត្តន៍ការការពារសង្គម និងធានាឲ្យមានការចូលរួមពីជនជាតិដើមភាគតិចឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពស្របទៅតាមកម្មវិធីរបស់ REDD+ ។ UN-REDD បានបញ្ចូល FPIC យ៉ាងពេញលេញ និងបានដឹកនាំដំណើរការ FPIC សាកល្បងក្នុងប្រទេសវៀតណាម និងប្រទេសឥណ្ឌូណេស៊ី ។

FCPF របស់ធនាគារពិភពលោក មិនបានដាក់បញ្ចូលគោលការណ៍ FPIC ចូលទៅក្នុងគោលនយោបាយ REDD+ របស់គេនៅឡើយទេ។ គោលនយោបាយប្រតិបត្តិការណ៍របស់ធនាគារពិភពលោកចំណុច ៤.១០ អំពាវនាវឲ្យប្រទេសទទួលជំនួយផ្សារភ្ជាប់ស្របទៅតាមពីការប្រឹក្សា ការចូលរួមដោយសេរី មានពត៌មានគ្រប់គ្រាន់ និងការឯកភាពជាមុន។ ទោះយ៉ាងណាក្តី ក៏ FPIC បានចាត់បញ្ចូលទៅក្នុងការតាក់តែងច្បាប់ជាតិក្នុងបណ្តាប្រទេសមួយចំនួន ក្នុងចំណោមនោះគឺមានប្រទេសហ្វីលីពីន ជាប្រទេសសមាជិកអាស៊ាន។ ដូច្នេះ ក្នុងបណ្តាប្រទេសទាំងអស់នេះ ការតាក់តែងច្បាប់ជាតិដែលដាក់បញ្ចូល FPIC នឹងជំនួសគោលនយោបាយរបស់ធនាគារពិភពលោក ។

## ការការពាររបស់ REDD+ : ធនាគារពិភពលោក និង UN-REDD

គោលនយោបាយការពាររបស់ធនាគារពិភពលោក, គោលនយោបាយប្រតិបត្តិការ និងនីតិវិធីដែលបានដាក់ស្នើ (ក្នុងនោះមាន 0P/BP 4.10 ស្តីពីជនជាតិដើមភាគតិច) ពាក់ព័ន្ធនឹងសកម្មភាពរបស់ FCPF និង FIP, ទាំងពីរសម្រាប់ធនាគារពិភពលោក និងបណ្តាប្រទេសដៃគូរនានា ។ គោលនយោបាយទាំងអស់នេះបង្កើតឡើងយ៉ាងសំខាន់ ដែលមានខ្លឹមសារលក្ខណៈជាគម្រោងនានា និងមិនមែនជាដំណើរការផែនការយុទ្ធសាស្រ្តទេ ។ ដូច្នេះ FCPF ចាប់ផ្តើមធ្វើការវាយតម្លៃសង្គម និងបរិស្ថានលក្ខណៈយុទ្ធសាស្រ្ត (SESA) ដែលការវាយតម្លៃនេះ ផ្តល់នូវលក្ខណៈវិនិច្ឆ័យចំពោះបញ្ហាសង្គម និងបរិស្ថានឲ្យទៅជាដំណើរការយុទ្ធសាស្រ្ត REDD+ ថ្នាក់ជាតិ ដើម្បីធានាថាសកម្មភាពដែលត្រៀមរួចហើយដែលគាំទ្រដោយ FCPF ឆ្លើយតបទៅនឹងគោលនយោបាយនានារបស់ធនាគារពិភពលោក ។

កម្មវិធី UN-REDD ដែលត្រួតពិនិត្យដោយមានការសន្យា និងមានការទទួលខុសត្រូវរបស់ UN រួមមានសេចក្តីប្រកាសសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច, ការយល់ព្រមបន្ទាប់ពីបានជ្រាបជាពត៌មានសព្វគ្រប់និងអាទិភាពដោយសេរី និងគោលការណ៍ណែនាំក្រុមការងារអភិវឌ្ឍន៍សហប្រជាជាតិស្តីពីជនជាតិដើមភាគតិច ។ ដូច្នេះ UN-REDD បច្ចុប្បន្ននេះ កំពុងបង្កើតគោលការណ៍ និងលក្ខណៈវិនិច្ឆ័យសង្គមនិងបរិស្ថាន (P&C) ដើម្បីធានាថាកាតព្វកិច្ចទាំងនេះ គឺមានចែងក្នុងកម្មវិធីរបស់ REDD+ ដើម្បីលើកកំពស់ផលប្រយោជន៍សង្គម និងបរិស្ថាន ហើយកាត់បន្ថយហានិភ័យពី REDD+ ។ P&C និងធានាថាសកកម្មភាពរបស់ REDD+ ឆ្លើយតបនឹងសេចក្តីការតាមប្រព័ន្ធរបស់ UN ។

បន្ថែមទៅនឹងការពារដែលមានរួចហើយ ឬការការពារថ្មីកំពុងតាក់តែងបង្កើតឡើងដោយភ្នាក់ងារទ្វេភាគី ឬពហុភាគី, អង្គការសង្គមស៊ីវិល និងសម្ព័ន្ធអ្នកដែលពាក់ព័ន្ធចម្រុះដូចជាៈ សម្ព័ន្ធអាកាសធាតុ ជីវៈចម្រុះ និងសហគមន៍ (CCBA),សម្ព័ន្ធព្រៃតំបន់ត្រូពិច (Rainforest Alliance) ឬក្រុមប្រឹក្សាគ្រប់គ្រងព្រៃឈើ (Forest Stewardship Council) ក៏បានបង្កើត ឬផ្តួចផ្តើចតាក់តែងនូវស្តង់ដារការពារផងដែរ ។

## ស្តង់ដារសង្គម និងបរិស្ថានរបស់ REDD+

សម្ព័ន្ធអាកាសធាតុ ជីវចម្រុះ និងសហគមន៍ (CCBA) និង CARE អន្តរជាតិ បានសម្របសម្រួលការតាក់តែងស្តង់ដារសង្គម និងបរិស្ថានរបស់ REDD+ (RDD+ SES) ។ RDD+ SES គឺជាលទ្ធផលនៃដំណើរការយល់ព្រម និងដាក់បញ្ចូលពាក់ព័ន្ធជាមួយរដ្ឋាភិបាល, អង្គការសង្គមស៊ីវិល, ក្រុមរបស់ជនជាតិដើមភាគតិច, ស្ថាប័នបង្កើតគោលនយោបាយនិងស្រាវជ្រាវ ក៏ដូចជាវិស័យឯកជនជាដើម ។ RDD+ SES មិនគ្រាន់តែស្នើសុំការគាំទ្រធ្វើផែនការ និងការអនុវត្តន៍កម្មវិធី REDD+ ថ្នាក់ជាតិ និងអនុជាតិដែលគោរពដល់សិទ្ធិជនជាតិដើមភាគតិច និងសហគមន៍ក្នុងតំបន់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតឲ្យមានផលប្រយោជន៍ដល់សង្គម និងបរិស្ថានផងដែរ។ ដូច្នេះ ស្តង់ដារលើសពីការការពារសង្គម និងបរិស្ថានអប្បបរមាទៅទៀត ដោយវាផ្តល់នូវផលប្រយោជន៍ជាច្រើន ។

**គោលការណ៍របស់ RDD+ SES គឺៈ**

១. សិទ្ធិកាន់កាប់ដីធ្លី ដែនដី និងធនធានដែលទទួលស្គាល់ និងគោរពទៅតាមកម្មវិធី REDD+ ។

២. ផលប្រយោជន៍របស់កម្មវិធី REDD+ ត្រូវបានបែងចែកស្មើៗគ្នា ទៅដល់អ្នកដែលមានសិទ្ធិពាក់ព័ន្ធទាំងអស់ ។

៣. កម្មវិធី REDD+ ជួយលើកកំពស់ការធានានូវជីវភាព និងសុខមាលភាពជនជាតិដើមភាគតិច និងសហគមន៍ក្នុងតំបន់រយៈពេលវែង ប្រកបដោយការយកចិត្តទុកដាក់ជាពិសេសទៅដល់ប្រជាជនដែលងាយរងគ្រោះជាងគេ ។

៤. កម្មវិធី REDD+ ចូលរួមចំណែកពង្រីកនូវការអភិវឌ្ឍន៍ប្រកបដោយចេរភាព ការគោរព និងគោលដៅការពារសិទ្ធិមនុស្ស និងអភិបាលកិច្ចល្អ ។

REDD+SES ថ្មីៗនេះកំពុងត្រូវបានយកទៅអនុវត្តន៍ក្នុងបណ្តាប្រទេសសាកល្បងមួយចំនួនក្នុងចំណោមនោះមានប្រទេសឥណ្ឌូណេស៊ី ដែលជាប្រទេសសមាជិកអាស៊ាន (នៅកណ្តាលខេត្ត Kalimantan)។

# អាស៊ាន REDD+ និងជនជាតិដើមភាគតិច

ដោយសារ RECOFTC- ជាមជ្ឈមណ្ឌលសម្រាប់មនុស្សនិងព្រៃឈើ ដែលមានទីតាំងស្ថិតនៅក្នុងទីក្រុងបាងកក-បានកត់សម្គាល់ឃើញ " ប្រទេសសមាជិកអាស៊ានទទួលស្គាល់ថា ប្រជាជននៅមូលដ្ឋានដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងព្រៃឈើ អាចជួយធ្វើឲ្យសម្រេចបានការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ហើយជួយលើកកំពស់សុខមាភាពប្រជាជនក្រីក្របាន។ បណ្តាប្រទេសអាស៊ានកំពុងប្រើប្រាស់ការទំនាក់ទំនងព្រៃឈើសង្គម ដើម្បីផ្តល់នូវផលប្រយោជន៍រួមគ្នានៃសង្គម វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថានឲ្យបានកាន់តែច្រើន ។ ១៨

ទោះបីយ៉ាងណា ក៏វិសាលភាពនៃសហគមន៍ព្រៃឈើក្លាយជាផ្នែកមួយនៃគោលនយោបាយព្រៃឈើជាតិខុសៗគ្នារវាងបណ្តាប្រទេសនីមួយៗ ដែលគួរឲ្យពិចារណា។ នៅក្នុងប្រទេសហ្វីលីពីន, សាធារណៈរដ្ឋប្រជាមានិត្យឡាវ និង





## ការចូលរួមដោយសេរី មានពត៌មានគ្រប់គ្រាន់ និងការឯកភាព ជាមុន

FPIC ជាយន្តការនិងដំណើរការអន្តរអំពើមួយ ដែលជនជាតិដើមភាគតិចប្រើប្រាស់ក្នុងការសម្រេចជាសមូហភាពរបស់ពួកគេ ដើម្បីឆ្លើយតបទៅលើបញ្ហាដែលប៉ះពាល់ដល់ពួកគេ ដូចជាការប្រើប្រាស់សិទ្ធិលើដីធ្លី ដែនដី និងធនធានរបស់ពួកគេ ហើយនិងសិទ្ធិកំណត់អត្តសញ្ញាណខ្លួនឯង និងតម្លៃវប្បធម៌។

**ចូលរួមដោយសេរី** ៖ ដំណើរការសម្រេចចិត្តដោយឯករាជ្យ

- ដោយគ្មានការបង្ខិតបង្ខំ ឬសេរីភាពក្នុងការបញ្ចេញមតិ ។ គ្មានការបញ្ឆោត ឬឥទ្ធិពលខាងក្រៅដែលបំបិទសិទ្ធិកំណត់អត្តសញ្ញាណខ្លួនឯង ក្នុងដំណើរការនាំទៅរកការសម្រេចចិត្ត
- ស្របនឹងច្បាប់ទំលាប់របស់ជនជាតិដើមភាគតិច
- ការយល់ស្របមិនមានសុពលភាពទេ ប្រសិនបើធ្វើឡើងដោយអាជ្ញាធរដែលមិនបានទទួលស្គាល់ និងទទួលខុសត្រូវចេញពីសហគមន៍ជនជាតិដើមភាគតិច

**ដឹងជាមុន** ៖ សិទ្ធិក្នុងការបញ្ចេញមតិ និងការសម្រេចចិត្ត មុនការអនុវត្តគម្រោងនោះ

- ការយល់ព្រមដោយផ្តល់ពត៌មានសព្វគ្រប់ត្រូវតែរកព្យាយាមស្វែងរកឲ្យបានគ្រប់គ្រាន់ក្នុងការអនុញ្ញាតចុងក្រោយឲ្យបានមុន ដោយរដ្ឋ ឬភាគីទីបី ឬផែនការសកម្មភាពសាកល្បងដែលមានផលប៉ះពាល់ដល់ជនជាតិដើមភាគតិច និងដីធ្លី ដែនដី និងធនធានរបស់ពួកគេ
- ពេលវេលាគ្រប់គ្រាន់ក្នុងការយល់ដឹង និងវិភាគនូវព័ត៌មានដែលទទួលបាននិងកំណត់ និងសម្រេចជាសមូហភាព
- តម្រូវការផ្សព្វផ្សាយព័ត៌មានក្នុងពេលមួយកំណត់ គួរតែសមស្របនឹងស្ថានភាពរបស់ជនជាតិ ដើមភាគតិច
- តម្រូវការពេលវេលានៃការពិគ្រោះយោបល់និងមតិរួមរបស់ជនជាតិដើមភាគតិច គួរតែកំណត់ដោយសហគមន៍ជនជាតិដើមភាគតិច និងពុំត្រូវដាក់កំហិតលើពួកគេទេ ។

**មានពត៌មានគ្រប់គ្រាន់** ៖ សិទ្ធិក្នុងការទទួលបានរាល់ព័ត៌មានចាំបាច់ និងព័ត៌មានពាក់ព័ន្ធនានា

- រួមមានការផ្តល់ពត៌មានដែលត្រឹមត្រូវ ពាក់ព័ន្ធការអភិវឌ្ឍន៍ដែលស្នើសុំក្នុងលក្ខណៈបែបបទមួយ និងភាសាមួយ ភាគីទាំងពីរអាចប្រើប្រាស់ និងយល់បានដែលពាក់ព័ន្ធសហគមន៍ជនជាតិដើមភាគតិច ។

**ការឯកភាព** ៖ ការយល់ស្រប ជាលទ្ធផលមួយនៃដំណើរការសម្រេចចិត្តបែបសមូហភាព ឯករាជ្យ និងកំណត់ខ្លួនឯងដោយសហគមន៍ជនជាតិដើមភាគតិច

- ជាទំរង់មូលដ្ឋាននៃការសំរេចចិត្តជាសមូហភាពរបស់សហគមន៍ មិនមែនគ្រាន់តែជាការសម្រេចចិត្តរបស់អ្នកដឹកនាំនោះទេ
- អាចមានលក្ខខណ្ឌនិងលក្ខខណ្ឌសំរាប់ធ្វើការសំរេចចិត្តសយល់ស្រប ដោយក្នុងនោះមានការបដិសេដ្ឋ ប្រសិនបើមានការបំពានលក្ខខណ្ឌនោះ
- គួរតែមាននៅគ្រប់រាល់ដំណាក់កាល ឬជំហ៊ាននៃគំរោង សកម្មភាព ប្រសិនបើដំណាក់កាលនីមួយៗ របស់គម្រោងនេះសុទ្ធតែចាត់ទុកថានឹងប៉ះពាល់ដល់ពួកគេ
- បទបង្ហាញនូវព័ត៌មានដែលត្រឹមត្រូវ និងមានប្រសិទ្ធភាព ការពិគ្រោះយោបល់ និងការចូលរួមគឺជាកត្តាដ៏សំខាន់ក្នុងដំណើរការនៃការយល់ស្រប
- ការរួមបញ្ចូលនូវទស្សនៈយេនឌ័រ និងការចូលរួមពីស្ត្រីជនជាតិដើមភាគតិច គឺជាកត្តាចាំបាច់ ក៏ដូចជាការចូលរួមរបស់កុមារ និងយុវជន គឺជារឿងសមស្រប។









វៀតណាម ទំហំព្រៃឈើយ៉ាងធំ ត្រូវបានគ្រប់គ្រងដោយសហគមន៍។ ប្រទេសកម្ពុជាមានបំណងពង្រីកតំបន់ព្រៃឈើសហគមន៍ស្របច្បាប់ឲ្យបានពី ១-១០% ។ យ៉ាងណាមិញក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូណេស៊ី មីយ៉ាន់ម៉ា និង ថៃ តំបន់ព្រៃឈើដែលគ្រប់គ្រងដោយសហគមន៍គឺមានទំហំតូចបើប្រៀបធៀបទៅ (តិចជាង ១%)។ [១៩]

របាយការណ៍ថ្មីៗដែលចេញដោយក្រុមអ្នកផ្តួចផ្តើមការការពារសិទ្ធិនិងធនធាន (RRI) ផ្តល់ភាពជាក់ស្តែងបន្ថែមទៀតដែលកំពុងទទួលស្គាល់សិទ្ធិចំពោះព្រៃឈើ ហើយកំពុងផ្ទេរអំណាចការគ្រប់គ្រងព្រៃឈើឲ្យដល់សហគមន៍ ដែលវាគឺជាកត្តាមួយដ៏សំខាន់ក្នុងការអភិរក្សព្រៃឈើប្រកបដោយជោគជ័យ ។ របាយការណ៍ដែលបានបោះពុម្ពថ្មីៗនេះ រកឃើញថាបណ្តាប្រទេសដូចជាចិន ឥណ្ឌា និងវៀតណាមនៅមិនទាន់ទទួលបានជោគជ័យក្នុងបញ្ឈប់ការកាប់បំផ្លាញព្រៃឈើទេ ប៉ុន្តែបានទទួលជោគជ័យក្នុងដាំឡើងវិញ និងបង្កើនតំបន់ព្រៃឈើទៅវិញ។ របាយការណ៍ក៏មានការសន្និដ្ឋាន ពីលទ្ធផលនៃការកែប្រែគោលនយោបាយ និងកំណែទម្រង់ ដែលផ្តល់សិទ្ធិបន្ថែមទៀតទៅដល់ជនជាតិដើមភាគតិច និងសហគមន៍ព្រៃឈើផ្សេងទៀត។[២០]

ប្រទេសឥណ្ឌូណេស៊ី ក៏បានប្រកាសពីការផ្លាស់ប្តូរគួរឲ្យចាប់អារម្មណ៍មួយក្នុងគោលនយោបាយព្រៃឈើរបស់ខ្លួននៅក្នុងសន្និសិទអន្តរជាតិស្តីពីសិទ្ធិកាន់កាប់ព្រៃឈើ អភិបាលកិច្ច និងសហគ្រាសដែលបានប្រារព្ធធ្វើឡើងនៅទីក្រុង Lombok ប្រទេសឥណ្ឌូណេស៊ី កាលពីខែមិថុនា ឆ្នាំ២០១១។ នៅក្នុងសារគន្លឹះរបស់ប្រមុខដឹកនាំនៃប្រធានអង្គភាព Special Delivery ឥណ្ឌូណេស៊ី (the head of the Indonesian President's Special Delivery Unit) លោក Kuntoro Mangkysubroto បានថ្លែងពីការយកចិត្តទុកដាក់របស់រដ្ឋាភិបាល ដើម្បីផ្តល់អាទិភាពសេចក្តីត្រូវការរបស់សហគមន៍ព្រៃឈើ ទទួលស្គាល់ គោរព និងការពារសិទ្ធិ Adat (ប្រពៃណី) ។ [២១]

ដំណើរការនៃការអនុវត្តន៍ REDD+ នៅក្នុងតំបន់អាស៊ាន គឺមិនដូចគ្នាទៅនឹងរាល់បណ្តាប្រទេសជាសមាជិកទាំងអស់នោះទេ។ បណ្តាប្រទេសសមាជិកអាស៊ានខ្លះ ដូចជាប្រទេសឥណ្ឌូណេស៊ី ប្រទេសវៀតណាម បានឆ្ពោះទៅមុខរួចហើយក្នុងជំហានដែលមានស្រាប់ តែផ្ទុយទៅវិញប្រទេសផ្សេងៗទៀត ការដំណើរការនៅយឺតយ៉ាវ ។ ប្រទេសមួយចំនួនដូចជាៈ ប្រទេសកម្ពុជា មានបទពិសោធន៍រួចហើយ ជាមួយគម្រោងសាកល្បងរបស់ REDD+ នៅមូលដ្ឋាន ។

និយាយជារួមទៅ ការអនុវត្តន៍ REDD+ នៅតំបន់អាស៊ាន គឺស្ថិតនៅជំហានដំបូងនៅឡើយ ។ យ៉ាងណាក៏ដោយ ក៏ជំហានដែលមានស្រាប់បច្ចុប្បន្ន គឺជាជំហានមួយដ៏សំខាន់ ដោយសារតែរដ្ឋាភិបាលសព្វថ្ងៃកំពុងតែរៀបចំយុទ្ធសាស្ត្រ REDD+ ថ្នាក់ជាតិ គម្រោងគោលនយោបាយ និងកំពុងណែនាំចំពោះការអនុវត្តន៍របស់វា។ ជនជាតិដើមភាគតិចភ័យខ្លាចថា គ្មានការពិគ្រោះយោបល់ និងការពាក់ព័ន្ធរបស់ពួកគេត្រឹមត្រូវ នោះគោលនយោបាយ និងយុទ្ធសាស្ត្រ

ទាំងអស់នេះអាចធ្វើឲ្យបាត់បង់សិទ្ធិ និងសុខមាលភាពរបស់ជនជាតិដើមភាគតិច និងសហគមន៍ដែលពឹងផ្អែកលើព្រៃឈើផ្សេងៗទៀត ។

លើកលែងតែប្រទេសវៀតណាម ដែលជាប្រទេសបានអនុវត្តន៍ដំណើរការ FPIC សាកល្បង គ្មានបណ្តាប្រទេសអាស៊ានណាមួយដែលបានពាក់ព័ន្ធទៅនឹង REDD+ បានដឹកនាំដំណើរការ FPIC ជាមួយជនជាតិដើមភាគតិចនៅតាមកម្រិតមូលដ្ឋានបានត្រឹមត្រូវទេ ។

នៅក្នុងប្រទេសឥណ្ឌូណេស៊ី មានការពិគ្រោះយោបល់មួយចំនួន ហើយរដ្ឋាភិបាលបានឆ្លើយតបចំពោះការផ្តល់យោបល់គោលនយោបាយមួយចំនួនពីជនជាតិដើមភាគតិច ប៉ុន្តែបញ្ហាសំខាន់ ជាពិសេសទៅលើការដឹកនាំ FPIC ជាមួយសហគមន៍ជនជាតិដើមភាគតិច ដែលមិនទាន់បានទទួលយកឲ្យបានពេញលេញនៅឡើយទេ ។ សន្និសិទព្រៃឈើអន្តរជាតិក្នុងទីក្រុង Lombok អាចធ្វើឲ្យយល់ដឹងផងដែរពាក់ព័ន្ធនឹងចំណុចផ្លាស់ប្តូរនេះ។ ជាលើកទីមួយហើយ ដែលសម្ព័ន្ធជនជាតិដើមភាគតិច AMAN ថ្នាក់ជាតិរបស់ប្រទេសឥណ្ឌូណេស៊ី ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចប្រជុំកម្រិតខ្ពស់ជាមួយក្រសួងរុក្ខាប្រមាញ់ ។ ក្រសួងរុក្ខាប្រមាញ់ ក៏បានយល់ព្រមជួបជាមួយអង្គការសង្គមស៊ីវិល ដើម្បីរៀបចំផែនការសកម្មភាព សម្រាប់ការអនុវត្តន៍ទៅលើការផ្តល់យោបល់នៅក្នុងសន្និសិទ្ធ រួមទាំងជំហានច្បាស់លាស់នានាឆ្ពោះទៅរកការផ្សព្វផ្សាយសិទ្ធិរបស់សហគមន៍ព្រៃឈើឥណ្ឌូណេស៊ី ។[២២]

នៅក្នុងប្រទេសឡាវ រដ្ឋាភិបាលនៅមិនទាន់ចូលរួមជាមួយជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិលនៅឡើយទេ ក្នុងបែបបទនៃការគាំទ្រ និងការកំណត់ទៅលើផែនការ REDD+ របស់ខ្លួន ។ ដំណើរឆ្ពោះទៅខាងមុខបង្ហាញឥរិយាបទ និងសកម្មភាពវិជ្ជមានក្នុងការពាក់ព័ន្ធជាមួយកម្មវិធីវិនិយោគព្រៃឈើ (FIP) ។ សិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ បានធ្វើឡើងក្នុងទីក្រុង Vientiane កាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ ដើម្បីបញ្ចប់ផែនការជាតិទៅលើ FIP ។ ក្នុងសិក្ខាសាលានេះដែរ ក៏មានការអញ្ជើញចូលរួមពីតំណាងមន្ត្រីគ្រប់ជាន់ថ្នាក់ ភ្នាក់ងាររដ្ឋាភិបាលតាមបណ្តាខេត្ត ស្ថាប័នធំៗ ក្រៅរដ្ឋាភិបាល សហជីពស្រ្តីឡាវ និងក្រុមហ៊ុនដោះស្រាយការសាងសង់ឡាវ កម្មវិធីទ្វេភាគីនិងពហុភាគី អង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់ (ហៅផ្លូវការថា ជាសមាគមន៍មិនរកប្រាក់ចំណេញ) អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងវិស័យឯកជន។[២៣]

មិនមានអ្វីដែលគួរឲ្យឆ្ងល់ទេ អាស៊ានមានរឿងរ៉ាវជាច្រើនដើម្បីចូលរួមចំណែកទាំងទៅលើការជម្រុញចំពោះការអភិរក្សព្រៃឈើ និងការធ្វើឲ្យទទួលបានជោគជ័យ។ តាមរយៈបណ្តាញព្រៃឈើសង្គមអាស៊ាន (ASFN) របស់ខ្លួន វាអាចដើរតួនាទីដឹកនាំជាពិសេសក្នុងការចែករំលែកបទពិសោធន៍ និងការជួយផ្សព្វផ្សាយសហគមន៍ដែលពឹងផ្អែកលើនីតិវិធីរបស់ REDD+ ។ RECOFTC ជឿជាក់ថា "ASFN បង្កើតឡើងមានតួនាទីយ៉ាងសំខាន់ ដើម្បីផ្សារភ្ជាប់អ្នកបង្កើតគោលនយោបាយព្រៃឈើរបស់រដ្ឋាភិបាល ជាមួយអ្នកដឹកនាំក្នុងសង្គមស៊ីវិល ការស្រាវជ្រាវការសិក្សា និងវិស័យឯកជន។ វាកំពុងធ្វើនៅក្រោមការគាំទ្ររបស់អាស៊ាន បណ្តាញនេះជួយផ្តល់ពត៌មានពីរបៀបវារៈគោលនយោបាយដល់មន្ត្រីព្រៃឈើជាន់ខ្ពស់ និងពង្រឹងជំនាញក្នុងចំណោមបណ្តាញចំណេះដឹងក្នុងតំបន់អាស៊ាន ASEAB ។[២៤]

លើសពីនេះទៀត អាទិភាព ១១ " ការគាំទ្រការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព (SFM) " ក្នុងផ្នែក D នៃផែនការសម្រាប់សហគមន៍សង្គម-វប្បធម៌អាស៊ាន (២០០៩-២០១៥) មានសកម្មភាព VIII ដែលព្យាយាមដើម្បី "ជម្រុញគាំទ្រការគ្រប់គ្រងព្រៃឈើពាក់ព័ន្ធសហគមន៍ដែលកំពុងរស់នៅក្នុង និង ជុំវិញតំបន់ព្រៃ ដើម្បីថែរក្សាព្រៃឈើឲ្យមាននិរន្តរភាព និងឲ្យប្រជាជនរស់នៅប្រកបដោយសុភមង្គល" ។







**ថវិការរបស់ FIP ដែលផ្តល់ឲ្យសម្រាប់សហគមន៍ក្នុងតំបន់ និងជនជាតិដើមភាគតិច**

FIP មានថវិការសម្រាប់ផ្តល់ឲ្យដល់សហគមន៍ក្នុងតំបន់ និងជនជាតិដើមភាគតិច ។ ផ្អែកទៅលើឯកសារគម្រោងរៀបចំថវិកានេះ ក្រុមអ្នកធ្វើសេចក្តីសម្រេចកម្រិតជាតិ និងពិភពលោកនឹងត្រូវរៀបចំបង្កើតឡើង ដែលជាអ្នកតំណាងឲ្យជនជាតិដើមភាគតិច និងសហគមន៍ក្នុងតំបន់ឲ្យបានទូលំទូលាយ។ ថវិកាដែលផ្តល់ឲ្យនេះ មានគោលបំណងដើម្បីបង្កើននិងពង្រឹងសកម្មភាពអភិរក្សព្រៃឈើប្រកបដោយនិរន្តរភាព លើកកម្ពស់ជីវភាពឲ្យមាននិរន្តរភាព ពង្រឹងសមត្ថភាពនិងការកាត់បន្ថយភាពក្រីក្រក្នុងចំណោមជនជាតិដើមភាគតិចនិងសហគមន៍ក្នុងតំបន់ ។ អ្នកតំណាងជនជាតិដើមភាគតិចដែលអញ្ជើញមកពីតំបន់ផ្សេងៗ ចូលរួមធ្វើគម្រោងស្នើសុំថវិកានេះបាន ។ ក៏មានកិច្ចប្រជុំពិគ្រោះយោបល់មួយផងដែរ ដែលបានប្រារព្ធធ្វើឡើងនៅសាធារណៈរដ្ឋប្រជាមានិត្យឡាវ ។ គេរំពឹងថាថវិកានេះនឹងត្រូវបានគេអនុម័តក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំ FIP (FIP Steering Committee) នៅខែវិច្ឆិកា ឆ្នាំ២០១១ ។





# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

ជនជាតិដើមភាគតិចជាច្រើនភ័យខ្លាចថាការអនុវត្តន៍កម្មវិធី REDD+ អាចមានផលប៉ះពាល់ដូចគ្នាចំពោះពួកគេ នៅពេលដែលមានការកំណត់នូវតំបន់អភិរក្សថ្មីៗ ដូចជាតំបន់សួនច្បារជាតិជាដើម។ ពួកគេយល់ដឹងពីការអនុវត្តន៍កម្មវិធី REDD+ ដោយសារការកំណត់ថ្មីបែបហ្នឹង ធ្វើឲ្យកើតមានជម្លោះ ការបង្ខំឲ្យមានការបំលាស់ទី ប៉ះពាល់ផ្នែករូបវន្តនិងសេដ្ឋកិច្ចអសន្តិសុខស្បៀង ការបាត់បង់ចំណូល និងការបាត់បង់ជីវចម្រុះនិងចំណេះដឹងអំពីប្រពៃណីដោយសារតែការឃាត់ឃាំង ការប្រកបជីវភាពតាមបែបប្រពៃណីរបស់ពួកគេ ការផ្លាស់ប្ដូរទីកន្លែងថ្មី ឬការបណ្ដេញពួកគេចេញ ។

ម្យ៉ាងវិញទៀត ការសិក្សាឯករាជ្យបានបង្ហាញថា ការអភិរក្សជីវចម្រុះ និងព្រៃឈើក្នុងភាពជាដៃគូបានល្អ និងស្ថិតក្រោមការរៀបចំការគ្រប់គ្រងសហការណ៍ជាមួយជនជាតិដើមភាគតិច ធ្វើឲ្យទទួលបានជោគជ័យច្រើន ហើយផ្ដល់ផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមកទៀតផង។ ភាពជាដៃគូទាំងអស់នេះ ពឹងផ្អែកទៅលើការគោរពសិទ្ធិ សេចក្ដីត្រូវការ និងយល់ដឹងបញ្ហារបស់ជនជាតិដើមភាគតិច ។ មេរៀនគន្លឹះមួយផ្សេងទៀតដែលបានរៀនសូត្រតាមរយៈបទពិសោធន៍ជាច្រើនទសវត្សមកហើយ ឆ្លើយតបជាមួយការអភិរក្សជីវចម្រុះនិងព្រៃឈើ គឺថាការគ្រប់គ្រងព្រៃឈើសហគមន៍ និងការអភិរក្សព្រៃឈើកាន់តែប្រកបទៅដោយនិរន្តរភាព និងកាន់តែផ្ដល់ផលប្រយោជន៍ស្មើគ្នានោះ លុះណាតែមានការយល់ដឹង និងការការពារសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍ ។

មានការរកឃើញសំខាន់ៗ ដែលត្រូវទទួលខុសត្រូវនៅក្នុងយុទ្ធសាស្ត្ររបស់ REDD+ ក្នុងការអភិវឌ្ឍន៍ជាតិ ។ REDD+ ផ្ដល់ឱកាសសម្រាប់ពង្រីកតំបន់ព្រៃឈើសហគមន៍តាមរយៈគោលនយោបាយ ប្រព័ន្ធច្បាប់ និងកំណែទម្រង់ស្ថាប័ន ដែលជួយពង្រឹងការការពារសិទ្ធិកាន់កាប់ដីធ្លី និងព្រៃឈើរបស់ជនជាតិដើមភាគតិច និងសហគមន៍ព្រៃឈើផ្សេងទៀត ។ វាថែមទាំងជួយកសាងសមត្ថភាពដល់ការរៀបចំការគាំទ្រដែលពាក់ព័ន្ធជាមួយភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវផងដែរ ។





ដូច្នេះវាត្រូវតែដឹងលឺយ៉ាងទូលំទូលាយថា អាស៊ានគួរតែលើកតម្កើននិងគាំទ្រការអនុវត្តន៍គោលការណ៍ចេញពីសហគមន៍ ហើយការការពារសង្គម និងបរិស្ថានឲ្យបានសកម្ម ដែលថ្មីៗនេះកំពុងតែអភិវឌ្ឍន៍ក្នុងយុទ្ធសាស្រ្ត REDD+ ថ្នាក់ជាតិ ក្នុងចំណោមប្រទេសសមាជិករបស់ខ្លួនដូចបានបង្ហាញខាងលើពាក់ព័ន្ធនឹង ASFN ។

ជនជាតិដើមភាគតិច និងក្រុមរបស់ពួកគេ ជាពិសេសក្នុងការពាក់ព័ន្ធជាមួយ REDD+ ផ្តល់អនុសាសន៍ ថា អាស៊ានគួរតែគាំទ្រ:

- ការយល់ដឹងពីសិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច ចំពោះការចូលរួមដោយសេរី មានពត៌មានគ្រប់គ្រាន់ និងការឯកភាពជាមុន (FPIC)
- ការទទួលស្គាល់ និងការពារសិទ្ធិជនជាតិដើមភាគតិច និងសហគមន៍ព្រៃឈើផ្សេងៗ ចំពោះការកាន់កាប់ដីធ្លី និងព្រៃឈើរបស់ពួកគេ
- ការចូលរួមរបស់ជនជាតិដើមភាគតិច និងសហគមន៍ព្រៃឈើផ្សេងៗទៀត និងក្រុមអ្នកតំណាងរបស់ពួកគេឲ្យបានសកម្ម និងប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តន៍កម្មវិធី REDD+ គ្រប់ដំណាក់កាល និងគ្រប់កម្រិត ក៏ដូចជាការរៀបចំផែនការគ្រប់គ្រងព្រៃឈើ និងការធ្វើសេចក្តីសម្រេចជាដើម
- ត្រូវធានាថាយន្តការនៃការបែងចែកផលប្រយោជន៍មានតម្លាភាព និងស្មើគ្នាត្រូវបានបង្កើតឡើងនៅក្នុង REDD+ ដែលផ្តល់រង្វាន់ដល់ជនជាតិដើមភាគតិច និងសហគមន៍ព្រៃឈើសម្រាប់ការការពាររបស់ពួកគេ និងបង់សំណងដល់ពួកគេចំពោះការបាត់បង់ចំណូលពីការប្រើប្រាស់ដីផ្សេង ហើយដែលពួកគេមានសេរីភាពដើម្បីសម្រេចលើបែបបទ និងលក្ខខណ្ឌនៃការបែងចែកផលប្រយោជន៍ជាសមូហភាព ។

ឆ្លើយតបចំពោះការចូលរួមរបស់អាស៊ានទៅនឹងបម្រែបម្រួលអាកាសធាតុ ជនជាតិដើមភាគក្នុងបានលើកឡើងនូវអនុសាសន៍ទៅកាន់អាស៊ានដូចខាងក្រោមៈ

- បង្កើតយន្តការសម្រាប់ការពិគ្រោះយោបល់ និងការចូលរួមរបស់ជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិលឲ្យបានជាប់លាប់ ក្នុងដំណើរការពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ដែលមានតម្លាភាព និងច្បាស់លាស់
- គោរពតាមភារកិច្ច និងការសន្យារបស់អន្តរជាតិ ឆ្លើយតបចំពោះការគោរពសិទ្ធិទៅលើជនជាតិដើមភាគតិច
- ធានាការចូលរួមរបស់ជនជាតិដើមភាគតិចឲ្យបានពេញលេញ និងប្រកបដោយប្រសិទ្ធភាពក្នុងការរៀបចំវិធានការ និងកម្មវិធីទាក់ទងនឹងការបន្សុំា និងការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ
- សម្រួលសម្រួល និង ផ្តល់ថវិកានិងធនធានសមស្រប ដើម្បីគាំទ្រការផ្តួចផ្តើមរបស់ជនជាតិដើមភាគតិចទៅលើការបន្សុំា និងការកាត់បន្ថយបម្រែបម្រួលអាកាសធាតុ ។









## ឯកសារយោង


១ AIPP, IWGIA និង វេទិកា-អាស៊ី ២០១០ ។ ជនជាតិដើមភាគតិចអាស៊ាន ។ ឯកសារសង្ខេប, ឈៀង ម៉ៃ, ទំព័រ ៤-៥

២ ធនាគារអភិវឌ្ឍន៍អាស៊ី ២០០៩ ។ សេដ្ឋកិច្ចនៃបម្រែបម្រួលអាកាសធាតុក្នុងតំបន់អាស៊ីអាគ្នេយ៍:ការពិនិត្យឡើងវិញក្នុងតំបន់, ទីក្រុង Mandaluyong, ប្រទេសហ្វីលីពីន: ធនាគារអភិវឌ្ឍន៍អាស៊ី, ទំព័រ xxii

៣ IPCC ២០០៧ ។ បម្រែបម្រួលអាកាសធាតុ ២០០៧: ផលប៉ះពាល់, ការបន្សាំ និងការងាយរងគ្រោះ។ ការចូលរួមរបស់ក្រុមការងារ II ចំពោះរបាយការណ៍វាយតម្លៃលើកទី៤ របស់ក្រុមការងារអន្តររដ្ឋាភិបាលស្តីពីបម្រែបម្រួលអាកាសធាតុ ២០០៧ . M.L. Parry, O.F. Canziani, J.P. Palutikof, P.J. van der Linden និង C.E. Hanson (eds). Cambridge University Press, Cambridge, United Kingdom and New York, NY, USA ។

៤ របាយការណ៍របស់អ្នកតំណាងជាន់ខ្ពស់សហប្រជាជាតិសម្រាប់សិទ្ធិមនុស្សស្តីពីទំនាក់ទំនងរវាងបម្រែបម្រួលអាកាសធាតុ និងសិទ្ធិមនុស្ស ។ A/ HRC/10/61, 15. មករា ២០០៩, ការបោះម្ពកែប្រែថ្មី ។ ដើម្បីធ្វើបទបង្ហាញនៅសម័យប្រជុំក្រុមប្រឹក្សាសិទ្ធិមនុស្សលើកទី១០ ខែមីនា ឆ្នាំ២០០៩ ។ របាយការណ៍នេះអាចស្វែងរកបាននៅគេហទំព័រ:: http://www2.ohchr.org/english/bodies/hrcouncil/docs/10session/A.HRC.10.61AEV.pdf

៥ អាស៊ាន ២០០៩ ។ ផែនការសម្រាប់សហគមន៍សង្គម-វប្បធម៌ (២០០៩-២០១៥) ។ អាចស្វែងរកបាននៅ: http://www.asean.org/22336.pdf, p. 21f

៦ Ibid ទំព័រ ២២ ។

៧ សេរីភាពពិតប្រាកដរបស់ខ្ញុំ (My Lucid Interval) ។ ប្លុករបស់ Atty. Zelda, ២០១១ ។ អាស៊ានជម្រុញឆ្ពោះទៅមុខពីតួនាទីរបស់ខ្លួន នៅក្នុងកិច្ចពិភាក្សាទៅលើអាកាសធាតុរបស់ UN នៅទីក្រុងបាងកក ។ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១១ ។ http:// attyzelda.wordpress.com/tag/asean/

៨ ធនាគារអភិវឌ្ឍន៍អាស៊ី ២០១០។ យុទ្ធសាស្ត្រ REDD+ ថ្នាក់ជាតិក្នុងតំបន់អាស៊ី និងប៉ាស៊ីភិច: ដំណើរការ និងការលំបាក ។ ទីក្រុង Madaluyong ប្រទេសហ្វីលីពីន: ធនាគារអភិវឌ្ឍន៍អាស៊ី, ទំព័រ ២






៩ អាស៊ាន ២០១០ ។ របាយការណ៍ថ្នាក់ដឹកនាំអាស៊ាន ស្តីពីការទទួលខុសត្រូវរួមគ្នាចំពោះបម្រែបម្រួលអាកាសធាតុ។ អាចស្វែងរកបាននៅ: http://www.asean.org/24515.htm

១០ អាស៊ាន ២០០៩ ។ op.cit., ទំព័រ ២២

១១ គោលការណ៍ពហុវិស័យស្តីពីបម្រែបម្រួលអាកាសធាតុអាស៊ាន ២០០៩ : កសិកម្ម និងព្រៃឈើឆ្ពោះទៅរកសន្តិសុខស្បៀង (AFCCFS)។ អាចរកបានតាមរយៈ http://ccmin.aippnet.org/pdfs/ASEANCCFrameworkANNEX%2013AFCCfinal. Pdf

១២ ពិនិត្យមើលឧទាហរណ៍: ធនាគារអភិវឌ្ឍន៍អាស៊ី ២០១០ ។ យុទ្ធសាស្រ្ត REDD+ ថ្នាក់ជាតិក្នុងតំបន់អាស៊ី និងប៉ាស៊ីភិច : ដំណើរការ និងការលំបាក។ ទីក្រុង Madaluyong ប្រទេសហ្វីលីពីន:ធនាគារអភិវឌ្ឍន៍អាស៊ី

១៣ RECOFTC ២០១១ ។ ព្រៃឈើសហគមន៍ និងឱកាសសម្រាប់ REDD+ ក្នុងតំបន់អាស៊ាន។ អាចស្វែងរកបាននៅ: http://www.recoftc.org/site/resources/ Community-Forestry-and-Opportunities-for- REDD-in-the-ASEAN-Region.php, p. 4

១៤ UNESCO ២០០៥,បណ្តាញការងារព្រៃឈើអាស៊ី ២០០៩ ។ តើអនាគតសម្រាប់ព្រៃឈើ និងវប្បធម៌នៅទីកន្លែងណា? ជនជាតិដើមភាគតិច និងការគ្រប់គ្រងព្រៃឈើក្នុងឆ្នាំ២០២០ ។ អត្ថបទស្រាវជ្រាវសិក្សាពីទស្សនៈវិស័យលើកទី II ទៅលើវិស័យព្រៃឈើតំបន់អាស៊ី-ប៉ាស៊ីភិច ។ អត្ថបទស្រាវជ្រាវលេខ. APFSOS II/WP/2009/23. Bangkok: FAO. អាចរកបាននៅគេហទំព័រ: http://www.fao.org/docrep/014/am618e/am618e00.pdf,p. 41

១៥ UNFCCC WG-LCA ២០១០ ។ លទ្ធផលការងាររបស់ក្រុមការងារ Ad Hoc ទៅលើសកម្មភាពប្រតិបត្តិរយៈពេលវែងស្របតាមអនុសញ្ញា។ Draft decision -/CP.16. Advance unedited version application/pdf/cop16_lca.pdf, p. 11

១៦ Ibid., ទំព័រ ២៤ ។

១៧ Ibid., ទំព័រ ២៥ ។

១៨ គេហទំព័រ RECOFTC http://www.recoftc.org/site/resources/ASEAN-Social-Forestry-Network

១៩ RECOFTC ២០១១, op.cit., ទំព័រ ៣

២០ អ្នកផ្តួចផ្តើមសិទ្ធិ និងធនធាន ២០១១ ។ បទបង្ហាញពី REDD របស់ Greener ។ មេរៀនសម្រាប់ REDD ចេញបណ្តាប្រទេសដែលមានតំបន់ព្រៃកំពុងកើនឡើង ។ ទីក្រុង Washington DC: អ្នកផ្តួចផ្តើមសិទ្ធិ និងធនធាន ។

២១ អ្នកផ្តួចផ្តើមសិទ្ធិ និងធនធាន ២០១១ ។ អត្ថបទចុះផ្សាយ: វេទិកាពិភពលោក, ការព្រមព្រៀងរបស់រដ្ឋាភិបាលឥណ្ឌូណេស៊ីដើម្បីពង្រឹងសិទ្ធិជនជាតិដើមភាគតិច និងសហគមន៍ព្រៃឈើ។ អាចស្វែងរកបាននៅ: http://www.rightsandresources.org/publication_details.php?publicationID=2519

២២ Idid ។

២៣ Chokkalingam, Unna ២០១១ ។ សិក្ខាសាលាពិគ្រោះយោបល់អ្នកពាក់ព័ន្ធដើម្បីបញ្ចប់ផែនការ FIP សម្រាប់ប្រទេសឡាវ ។ គេហទំព័រ កាបូនព្រៃឈើ នៅអាស៊ី http://www.forestcarbonasia.org/ in-the-media/stakeholder- consultation-workshopto-finalize-forest-investment-program-plan-for-laos/

២៤ គេហទំព័រ RECOFTC : http://www.recoftc.org/site/resources/ASEAN-Social-Forestry-Network



**បោះពុម្ពដោយក្រុមការងារអន្តរជាតិទៅលើកិច្ចការជនជាតិភាគតិច (IWGIA)**
**និង កតិកសញ្ញាជនជាតិភាគតិចនៅអាស៊ី (AIPP)**
ក្រោមជំនួយឧបត្ថម្ភពីមូលនិធិទីភ្នាក់ងារន័រវ៉េសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (Norad)
និងក្រសួងកិច្ចការបរទេសដាណាម៉ាក (Danish)
ទីក្រុងឈៀងម៉ៃ ឆ្នាំ ២០១១

IWGIA: www.iwgia.org
AIPP: www.aippnet.org
អត្ថបទ និងរូបភាពដោយ: Christian Erni
បោះពុម្ពនៅទីក្រុងឈៀងម៉ៃ ប្រទេសថៃដោយ AIPP Printing Press Co. Ltd.